សារព័ត៌មាន ខ្មែរប៉ុស្តិ៍ ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធនា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

Cambodia daily

## HUMAN RIGHTS WATCH SLAMS 'NEITHER FREE NOR FAIR' ELECTIONS

**by Chhorn Phearun | June 14, 2017**

Human Rights Watch (HRW), long one of the government's harshest critics, on Tuesday condemned the June 4 commune elections as "neither free nor fair" and called for urgent reforms to safeguard next year's national election.

While echoing a view from other international observers, including the E.U. and the U.S. Embassy in Phnom



លោក ប្រេដ អាដាម នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ី ។ រូបថត : Reuters

Penh, that Election Day itself was "peaceful," the New York-based organization slammed Cambodia's pre-election atmosphere, saying the vote "took place

**Continued to Page 12**

# វិទ្យាល័យឡូវែល: សាលាក្រុងសម្រេចយក ខលី

**ដោយ ពិន សំខុន**

ថ្ងៃសំខាន់ដែលសម្រេចបញ្ចប់ការខ្វែងយោបល់ យកទីតាំងវិទ្យាល័យឡូវែលប្តូរទៅ "ខលី" ឬក៏ កែលំអរនៅទីតាំងដដែល"ដោនថោន"បានមកដល់, ថ្ងៃអង្គារទី២០ មិថុនា២០១៧ ក្រុមប្រឹក្សាក្រុងឡូវែលនឹងធ្វើការបោះឆ្នោតជាប្រវត្តិសាស្ត្របន្ទាប់ពីពន្យាលើកពេលច្រើនដងមក។ រាត្រីទី២០ វេលាម៉ោង១២អាធ្រាតសមាជិកក្រុមប្រឹក្សាក្រុងឡូវែល៩រូបបានបោះឆ្នោតសម្រេចបានលទ្ធផល"ដោនថោន"បាន ៤សម្លេង ( មានទាំងសម្លេងឆ្នោតចៅហ្វាយក្រុងខេណ្ណឺឌីផង) ទល់នឹង "ខលី" បាន៥សម្លេង ដូច្នេះវិទ្យាល័យឡូវែលនឹងទៅសង់នៅខលី តាមសេចក្តីសម្រេចភាគច្រើនរបស់សមាជិកក្រុមប្រឹក្សាក្រុងឡូវែល ។ លទ្ធផល

**តទៅទំព័រទី០៣**








ក្រុមប្រឹក្សាក្រុងឡូវែលបោះឆ្នោតឱ្យ ខលី មាន
-រីដា មីសៀ
-រ៉ដនី អ៊ីលីយ៉ុត
-ជីម លើរី
-ដាន់ រូក
-កូរី បាលែងជី




## គណកម្មការសំណង១៨រូប ៩រូបបោះឆ្នោត ខលី

កាលពីព្រឹកថ្ងៃទី២០ ដដែល -រ៉ាឌី ម៉ម និងខេវិន ម៉ហ្វី បោះឆ្នោតឱ្យ ខលី

Murphy Cawley 5, Kennedy 3, Elliott Cawley5, Gendron3, Khelfaoui 3, Underfood 3, Martin 3, Frisch Cawley5, Tsapatsaris3, Baldwin Cawley5, Beati Cawley5, Cook 3, Samaras3, Healy Cawley 5, Mom Cawley5, Ballotta Cawley5, Mason 3





មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ





978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com

សារព័ត៌មាន ខ្មែរប៉ុស្តិ៍ ស.រ.អា KhmerPost USA
Cambodian American Biweekly Newspaper
Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:
Massachusetts:
- Lowell
- Lynn/Revere
Rhode Island:
- Providence
- Cranston
CELEBRATING 10 YEARS
Contact us for the Advertising Opportunity!
978-677-7163 | http:/khmerpost.us

## បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

## អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784
**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយ:កម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

តមកទំព័រទី ០១

## វិទ្យាល័យឡូវែល : សាលាក្រុងសម្រេច...

នេះបានធ្វើឱ្យពលរដ្ឋឡូវែលប្រមាណជា៣០០នាក់ ដែលបានមកចូលរួមស្តាប់កិច្ចប្រជុំរហូតដល់ចប់នៅម៉ោង១កន្លះព្រឹក មានប្រតិកម្មខុសៗគ្នាដោយសារការប្រកាន់យកទស្សនៈខុសៗគ្នាពីទីតាំងនៃការសង់ថ្មីនៅកន្លែងថ្មីស្របនឹងគំនិតវិទ្យាល័យនៃ"សតវត្សទី២១" ឬកែរលំអលើទីតាំងចាស់នៃ "សំណង់ប្រវត្តិសាស្ត្រ"នោះ ។









ទិដ្ឋភាពក្នុងសាលាក្រុងឡូវែលពេលបោះឆ្នោតនាថ្ងៃទី២០ មិថុនា វេលាម៉ោង១២យប់



សម្លេងឆ្នោតប្រកាន់យកទីតាំងនៅ"ខលី" មានលោកស្រីសមាជិកក្រុមប្រឹក្សា រីដា មើសៀ ដែលមានការប្រាកដប្រជាខ្លាំងខ្លាក្នុងការសម្រេចចិត្តយកទីតាំង"ខលី"ប្រឈមមុខនឹងការទិទានឬគម្រាមពីអ្នកដែលចូលចិត្តយកទីតាំង"ដោនថោន", បន្ទាប់មកមានលោក រ៉ែតនី អេលីយ៉ុត ដែលទាមទារឱ្យអង្គប្រជុំប្រព្រឹត្តទៅដូចគម្រោងមិនឱ្យពន្យាពេលតទៅទៀត លោកមានការច្បាស់លាស់ក្នុងជំនឿ"ខលី"គឺជាអនាគតរបស់ឡូវែលតាំងពីយូរមកហើយ, រួចមកមានលោក ជីម ឡេរី ដែលជាអ្នករើកកាយពីការខ្វះចន្លោះក្នុងការពន្យល់ពលរដ្ឋម្ចាស់ពន្ធទាំងខុសថា ទីតាំង"ខលី"បានបង្កើនចំណាយលើសពី"ដោនថោន"ហើយលោកបានបន្ទោសវិគ្គិនដែលឡើងមកសម្តែងមតិថា មិនមាននរណានិយាយពីផលប្រយោជន៍នៃសាលារៀនសម្រាប់កូនសិស្សសោះពីព្រោះនោះហើយជាបុព្វហេតុនាការសម្រេចចិត្តដ៏សំខាន់នារាត្រីនេះ, លោក ដាន់ រួក មានតួរនាទីជាចៅហ្វាយក្រុងរងមិនបាននិយាយអ្វីច្រើនទេ តែលោកបានបង្ហាញទស្សនៈលោកនៅក្នុងសារព័ត៌មានខ្មែរផុសរួចហើយពីហេតុផលរបស់លោកដែលបានសម្រេចយកទីតាំង"ខលី", រីឯអ្នកដែលបានធ្វើឱ្យក្រុម "ដោនថោន"ខកចិត្តជាងគេគឺលោក កូរី បាឡិនជ័រ ជាសមាជិកក្រុមប្រឹក្សាទី៩ដែលបានធ្វើឱ្យសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុងឡូវែលឃ្លោងពី "ដោនថោន"ទៅរក"ខលី"វិញ ពីព្រោះលោកយល់ថា សកម្មភាពរបស់លោកតាំងពីច្រើនឆ្នាំមកហើយគឺបំរើការអភិវឌ្ឍន៍ឡូវែលដោយប្រឹងប្រែងហើយបានឃើញឱកាសដែលឡូវែលកំពុងតែផ្លាស់ប្តូរស្របនឹងចក្ខុវិស័យពង្រឹងសេដ្ឋកិច្ចឡូវែលផងនឹងផ្តល់វិស័យអប់រំសតវត្សទី២១ដល់យុវជនឡូវែលផង ក្នុងគំនិតនេះលោកមិនខ្លាចនឹងការគម្រាមមិនបោះឆ្នោតឱ្យលោកនាខែវិច្ឆិការខាងមុខនោះទេ ។

**ក្រុមប្រឹក្សាក្រុងបោះឆ្នោតឱ្យ "ដោនថោន": អភិបាលក្រុង អែដ ខេណើឌី -ជីម មីលីណាហ្សូ -ជន លីហ៊ី និង ប៊ីល សាមា រ៉ាស់**

សមាជិកក្រុមប្រឹក្សាដែលបានបោះឆ្នោតយក"ដោនថោន"មានលោកអភិបាលក្រុង អេដ ខេណ្ណីឌី, មានលោកសមាជិកក្រុមប្រឹក្សាមេលីណាស្ហូ, លោក ប៊ីល សាម៉ារ៉ាស នឹងលោក ចន លីហ៊ី ដែលមានមតិជាទូរទៅ ចង់រក្សាអគិាជាប្រវត្តិសាស្ត្របន្តមរតកនៃបុព្វបុរសកាលពី១សតវត្សមុនឱ្យនៅកន្លែងដដែលមក ។

នារាត្រីទី២០នោះ អ្នកគាំទ្រយកទីតាំង "ខលី" បានបញ្ចេញយោបល់ថា ១-ឱកាសដែលរដ្ឋបញ្ចេញប្រាក់ជិត៤០០លានដុល្លាមកឱ្យរៀបចំវិទ្យាល័យសាជាថ្មី ជាឱកាសដ៏កម្រខ្លាំងណាស់ គួរតែឆ្លៀតឱកាសរៀបចំវិទ្យាល័យនេះឱ្យស្របតាមសេចក្តីត្រូវការរបស់ការអប់រំនាសម័យសតវត្សទី២១ មធ្យោបាយមានតែ១ គឺគម្រោងថ្មីនៅនៅលើទីតាំងថ្មី ទើបអាចធ្វើទៅបាន ២-ការមិនយល់ស្របយកទីតាំងចាស់ គឺអាគារមានការទ្រុឌទ្រោមខ្លាំងណាស់ហើយ មានការជួសជុលច្រើនដងអស់ថវិការច្រើនសិបលានដុល្លាហើយនៅតែមិនអាចឆ្លងការត្រួតពិនិត្យរដ្ឋបាននៅឡើយ ដូច្នេះអាចនឹងមានការគ្រោះថ្នាក់បន្តរទៅទៀតនៅថ្ងៃមុខបាន, ទីធ្លាក៏មិនធំទូលាយសម្រាប់តែសាលារៀនទេ តែនៅក្នុងក្រុងទាំងមូលដែលមិនអាចធ្វើឱ្យសេដ្ឋកិច្ចក្រុងឡូវែល រីកចំរើនទៅបាន ដោយសារតែភាពចង្អៀតចង្អល់កាន់តែខ្លាំងឡើងនេះដែរ ៣-វិទ្យាល័យដែលនៅមិនឆ្ងាយពីលំនៅឋានមានសិស្សអាស៊ីជាច្រើននាំគ្នាដើរពីផ្ទះ កាត់ក្រុង ដើម្បីទៅសាលារៀន តែវិធីនេះក៏មានមាតាបីតាជាច្រើនមានកង្វល់ថា: មិនផ្តល់សុវត្ថិភាពនឹងភាពងាយស្រួលដល់ការធ្វើដំណើររបស់សិស្សទេ ៤-បើមានការប្តូរទីតាំងសាលាទៅក្រៅក្រុងនៅ "ដោនថោន" គេអាចកែរលំអពង្រីកទៅជាមណ្ឌលសេដ្ឋកិច្ចដែលអាចរកប្រាក់ចំណូលពន្ធដារបានច្រើនជាងមុនតំបន់ទាំងមូលនឹងបានប្តូរមុខមាត់ផង -ម្យ៉ាងទៀតនៅពេល៤-៥ឆ្នាំនៃការសាងសង់សាលាថ្មីមិនរំខានដល់ការសិក្សារបស់នឹងការបង្រៀនរបស់គ្រូមួយជំនាន់នោះទេ ។

នៅរាត្រីដដែលនោះអ្នកដែលគាំទ្រឱ្យសាលានៅ"ដោនថោន"បានមើលឃើញហើយបញ្ចេញយោបល់ថា: ១-វិទ្យាល័យឡូវែលនៅលើទីតាំងចាស់បានបំពេញតួនាទីរបស់ខ្លួនបានល្អឥតខ្ចោះទទួលកេរ្តិ៍ឈ្មោះល្អជាសាលាដែលនៅក្នុងចំណោមសាលាដែលមានឈ្មោះល្បីក្នុងប្រទេសផង ២-នៅកណ្តាលក្រុងវិទ្យាល័យបានអនុញ្ញាតឱ្យសិស្សគ្រប់ពណ៌សម្បុរមករៀនចម្រុះដោយគ្មានទំនាស់គ្មានការប្រកាន់គ្នាសិស្សក៏អាចដើរមកសាលារៀនបានទៅកន្លែងសិក្សាបន្ទាប់ម៉ោងរៀនទៅបណ្ណាល័យរដ្ឋដោយទីទាំងនោះនៅមិននៅឆ្ងាយពីផ្ទះសម្បែងខ្លួនផង ៣-ចំណែកថវិការជួសជុលឱ្យទៅជាថ្មីវិញនោះ ក៏នឹងមិនធ្វើឱ្យអ្នកបង់ពន្ធធ្ងន់ធ្ងរឡើយ ។ តែនារាត្រីថ្ងៃទី២០នោះ វាគ្មិនជាច្រើនដែលគាំទ្រ "ដោនថោន"នាំគ្នាទាមទារមិនឱ្យសមាជិកក្រុមប្រឹក្សាជាអ្នកសម្រេចយកទីតាំងទេ បែរជាសុំឱ្យមានការបោះឆ្នោតជាសាធារណមួយជា"អ្នកសម្រេចយកទីតាំង"នាពេលក្រោយទៅវិញ ។

នៅលើសំណើរចុងក្រោយរបស់អ្នកគាំទ្រ "ដោនថោន"នេះ លោកអភិបាលក្រុង ខេណ្ណីឌី បានស្នើឱ្យអង្គប្រជុំក្រុមប្រឹក្សាក្រុងសម្រេច តែអង្គប្រជុំបានទាត់ចោលដោយសម្លេង៥ទល់នឹង៤នៅម៉ោង១១.៤៥អាធ្រាត ពីព្រោះសំណើរដដែលនេះបានស្នើម្តងហើយ ដោយលោកសមាជិកក្រុមប្រឹក្សាក្រុង រ៉ែតនីយ អេលីយ៉ុត ដែលគាំទ្រ "ខលី" កាលពីខែមុន ក៏បានត្រូវទាត់ចោលដូចគ្នា ។

ថ្វីត្បិតតែសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុងឡូវែល បានប្រព្រឹត្តទៅអស់រយៈពេលរហូតដល់៦ម៉ោងក៏ដោយក្រុមប្រឹក្សាបានស្តាប់យោបល់វាគ្មិនទាំងអស់( ប្រមាណជិត៧០នាក់) យ៉ាងយកចិត្តទុកដាក់ ហើយបានផ្តល់សេចក្តីសម្រេចចិត្តយ៉ាងប្រុងប្រយ័ត្នប្រកបដោយការគោរពច្បាប់នឹងគោរពស្មារតីនៃលិទ្ធិប្រជាធិបតេយ្យគ្មានសល់ចន្លោះ រហូតដល់បានសេចក្តីសម្រេចចិត្តដ៏លំបាកមួយ ដែលការបែងចែកសង្គមជា២នៅជ្រងោពីមុខការទទួលខុសត្រូវនៃសមាជិកក្រុមប្រឹក្សាក្រុងឡូវែលទាំងអស់ ។

នៅក្នុងទំព័រនៃព័ត៌មានសង្គម នាថ្ងៃបន្ទាប់មក គេហាក់ពុំទាន់ឃើញឡូវែលត្រឡប់មករកការចុះសម្រុងគ្នា ដើរទៅរកការកសាង "ខលី" នៅឡើយទេ, ខាង "ដោនថោន" មានការអាក់អន់ស្រពន់ចិត្តចង់បន្តសកម្មភាពធ្វើឱ្យមានការប្តូរសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាក្រុង ដោយប្រកូកឱ្យពលរដ្ឋចុះហត្ថលេខាឱ្យបានច្រើនតវ៉ាឱ្យយកការបោះឆ្នោតធ្វើសេចក្តីសម្រេចចិត្តមួយទៀតនៅខែវិច្ឆិការខាងមុខដោយសម្លេងឆ្នោតពលរដ្ឋឡូវែលវិញម្តង ។ បើធ្វើមិនបានទេ រដ្ឋនឹងចុះហត្ថ

តទៅទំព័រទី ០៥

# ពលរដ្ឋខ្មែរ៥ នាក់ត្រូវបានសង្គ្រោះក្នុងករណីគ្រោះថ្នាក់នៅសមុទ្រ

**ដោយ សុខារ័ត្ន កួយ**

កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧ដែលជាថ្ងៃបុណ្យឪពុក កាណូតស្ទូចត្រីដែលមានពលរដ្ឋខ្មែរចំនួន៩ នាក់បានជួបគ្រោះថ្នាក់លិចនៅម៉ោងប្រហែលជា៩:៤៥ ព្រឹកព្រលឹមបន្ទាប់ពីកាណូតបានបើកបុកប៉ះទៅនឹងថ្មតែមិនបង្កឱ្យនរណាម្នាក់រងរបួសធ្ងន់ធ្ងរនោះទេ។

ក្នុងករណីនេះ ពលរដ្ឋខ្មែរទាំង៥នាក់ក្នុងនោះមានស្ត្រីម្នាក់ផងដែរ ត្រូវបានជួយសង្គ្រោះដោយក្រុមប៉ូលិសWharehamបន្ទាប់ កាណូត ត្រូវបានរកឃើញនៅទីតាំងដែលមានទឹករាក់ និងតំបន់ដែលសំបូរទៅដោយថ្មនៅចំណុចជិតកោះ Little Bird Island ស្ថិតនៅក្រុង Wareham ក្នុងរដ្ឋម៉ាសាជូសេតដែលជាប់និង Rhode Island។

លោកស្រី ឡាំ ផុង ជនរងគ្រោះជាស្ត្រីតែម្នាក់ក្នុងចំណោមជនរងគ្រោះទាំង៥ បានឱ្យខ្មែរផុសដឹងថា នៅថ្ងៃកើតហេតុ លោកស្រី និងស្វាមីព្រមទាំងមិត្តភ័ក្រពនាក់ផ្សេងទៀត បានបើកកាណូតក្នុងគោលបំណងដើម្បីទៅស្ទូចត្រី តែមិនទាន់បានទៅដល់គោលដៅផង កាណូតបានបុកប៉ះទៅនឹងថ្មត្រង់កន្លែងម៉ាស៊ីនធ្វើឱ្យម៉ាស៊ីនមានបញ្ហា។

លោកស្រីបន្តទៀតថា បន្ទាប់ពីបានបុកប៉ះត្រូវម៉ាស៊ីនអ្នកជិះលើកាណូតទាំងអស់ចាប់ផ្តើមពាក់អាវពោង ហើយអ្នកបើកបរបានព្យាយាមបញ្ឆេះរោលម៉ាស៊ីនក្នុងគោលបំណងដើម្បីធ្វើដំណើរបន្តតែបែជាធ្វើឱ្យទឹកហូរចូលកាណូតកាន់តែច្រើន ហើយផ្សៀងលិចតែមិនបង្កឱ្យកាណូតលិចបាត់តែនោះទេ។

ដោយសារតែជនរងគ្រោះពុំស្គាល់ទីកន្លែងកើតហេតុច្បាស់លាស់សកម្មភាពជួយសង្គ្រោះត្រូវបានចំណាយពេលរហូតដល់ប្រមាណជិត១ម៉ោងទំរាំក្រុមប៉ូលីសអាចកំណត់ទីតាំងកើតហេតុនិងធ្វើការជួយសង្គ្រោះបាន។ លោកស្រីឡាំ ផុង ថា ក្នុងចំណោម៥នាក់មានតែម្នាក់ប៉ុណ្ណោះ ដែលរងរបួសជើងបន្តិចបន្តួចដោយសាររអិលនៅពេលកាណូតផ្សៀងលិច...។

នេះគឺករណីលិចកាណូតនៅសមុទ្រលើកទី២ ហើយបន្ទាប់គ្រោះថ្នាក់លិចកាណូតស្រដៀងគ្នានេះដែរបានកើតឡើងកាលពីថ្ងៃអង្គារទី៦ មិថុនា ២០១៧ ដោយសារតែខ្យល់ព្យុះរលកធំដែលបណ្តាលឱ្យពលរដ្ឋខ្មែរម្នាក់គឺលោក ឈៀង ឈុន បានលង់ទឹកស្លាប់។

ដើម្បីសុវត្ថិភាព និងត្រៀមខ្លួន ដើម្បីបង្ការគ្រោះថ្នាក់ដល់ជីវិតនៅពេលជួបបញ្ហាបន្ទាន់នៅសមុទ្រក្នុងករណីក្រឡាប់ទូក ត្រូវចាំថា កាក្រឡាប់ទូកអាចកើតមានគ្រប់ពេលវេលាបើទោះជាលោកអ្នកមានបទពិសោធន៏ ឬកាណូតមានសុវត្ថិភាពយ៉ាងណាក៏ដោយ, ត្រូវតែពាក់អាវពោងជានិច្ចសម្រាប់កាណូតតូច, ត្រូវប្រាកដថាយ៉ាងហោចណាស់លោកអ្នកមានវិធី២ ក្នុងការទំនាក់ទំនងមកកាន់អ្នកនៅលើគោក, ត្រូវមានគ្រាប់រំសេវភ្លើងសញ្ញាជួយសង្គ្រោះដែលអាចប្រើបានទាំងយប់និងថ្ងៃ, និងត្រូវប្រាកដថា លោកអ្នកអាចចាប់យកឧបករណ៏ចាំបាច់សំខាន់ៗរបស់លោកអ្នកដោយងាយស្រួល។

ក្នុងករណីលលិចទូកត្រូវប្រាកកដថា ម្នាក់ៗពាក់អាវពោងបានត្រឹមត្រូវព្យាយាមស្វែងរកប្រភពដែលបង្កឱ្យលិច និងកាត់បន្ថយកន្លែងដែលទឹកហូរចូលដោយយកអ្វីមួយទៅបិទប្រហោងនោះ, ហៅរកជំនួយ និងព្យាយាមឆ្ពោះទៅរកទឹករាក់ព្រមទាំងបាចទឹកចេញពីទូកឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយសំខាន់បំផុតត្រូវនូវជាប់ជាមួយទូករឺកាណូតដោយសារឱកាសក្នុងការដែលគេអាចស្វែងរកឃើញមានច្រើន៕


រូបភាពកាណូតដែលបានលិចដោយសាបុកនិងថ្ម (ប្រភព: 25 Boston)


រូបភាពជនរងគ្រោះដែលត្រូវបានជួយដោយឆ្មាំសមុទ្រ






តមកទំព័រទី ០៣
## វិទ្យាល័យឡូវែល ៖ សាលាក្រុងសម្រេច...

លេខាប្រគល់ប្រាក់សំណង់មកឡូវែលនៅខែកុម្ភៈ ២០១៨ ហើយផ្តើមសំណង់ "ខលី" ជាបន្ទាប់ភ្លាមដែរ ។ បើសម្លឹងទៅខាងសមាជិកក្រុមប្រឹក្សាក្រុងគេមិនទាន់ឃើញមានសញ្ញាណាមួយថា បន្ទាប់ពីបោះឆ្នោតយក "ខលី" រួចហើយ សមាជិកក្រុមប្រឹក្សាមានការបែកបាក់គ្នាទេ ភាពចុះសម្រុងគ្នាឃើញត្រឡប់មកនៅមានដូចមុនដដែល ។

## លោក អេដ ខេណ្ណីឌី នៅបន្តប្រតិកម្មទប់ទល់"ខលី"

ថ្វីត្បិតតែការបោះឆ្នោតមិនបានលទ្ធផលនៅសាលាក្រុង ដូចសេចក្តីប្រាថ្នារបស់លោក អេដ ខេណ្ណីឌី ក៏ដោយលោកអភិបាលក្រុងនឹងនៅតែបន្តរប្រតិកម្មនៅក្រុមប្រឹក្សាសាលារៀន (School committee) ថែមមួយទៀត ដោយសារលោកមានតួរនាទីជាប្រធានរបស់គណកម្មការនោះដែរ ។ ទីប្រឹក្សាច្បាប់និយាយថា "សាលាក្រុងមានអំណាចគ្រប់គ្រាន់នឹងធ្វើសេចក្តីសម្រេចបាន" ហើយបន្តថា៖ គណកម្មការសាលារៀន "គ្មានអំណាចធ្វើសេចក្តីសម្រេចលើទីតាំងវិទ្យាល័យនោះទេ" ប៉ុន្តែលោក អេដ ខេណ្ណីឌី នៅតែបន្តឱ្យមានការបោះឆ្នោត "យកខលីឬដោនថោន" ក្នុងគណកម្មការសាលារៀននៅថ្ងៃពុធខាងមុខនេះដដែល ។ លោក អេដ ខេណ្ណីឌី ពេលខែមុននេះសោះធ្លាប់ប្រឆាំងនឹងសំណើររបស់លោក រ៉តនី អេលីយ៉ុត នឹង កូរី បាឡិនជ័រ មិនឱ្យធ្វើ "ប្រជាមតិ" នោះ ស្រាប់តែពេលនេះមិនបានរក្សាពាក្យរបស់លោកនឹងនៅតែតស៊ូបើទោះជាមិនស្របច្បាប់ក៏ដោយ ៕



## ប្រយ័ត្នចំពោះការបរិភោពត្រីកាម៉ុងចំហុយ

**ប្រែសម្រួលដោយខ្មែរផុស ស.រ.អា**

**ញូយក–** ត្រីកាម៉ុង រឺត្រីផ្លាធូចំហ៊ុយរបស់ក្រុមហ៊ុន Willis Ocean Inc ដែលមានទីតាំងនៅក្រុងប្រូគ្លីន រដ្ឋញ៉ូយក បានត្រូវប្រកាសប្រមូលត្រឡប់ចូលក្រុមហ៊ុនវិញ និងជូនដំណឹងពីសុវត្ថិភាព កាលពីថ្ងៃទី១៤ ខែមិថុនា បន្ទាប់ពីការិយាល័យគ្រប់គ្រងចំណីអាហារនិងឱសថអាមេរិកបានរកឃើញថាផលិតផលត្រីចំហ៊ុយរបស់ក្រុមហ៊ុនមិនត្រូវបានវះយកគ្រឿងក្នុងចេញនោះទេ ។

ត្រីកាម៉ុងចំហ៊ុយរបស់ក្រុមហ៊ុន Willis Ocean Inc ត្រូវបានចែកចាយទៅកាន់ហាងលក់រាយទូទាំងប្រទេស ដោយមានការ៉ុចខ្ចប់ជាមួយទ្រនាប់ស្នោរពណិសដែលមានត្រីកាម៉ុងចំនួន២រុំជិតដោយថងផ្លាស់ស្ទីកថ្លានឹងមានផ្លាកសញ្ញាពិណក្រហមដែលសសេរ "ផលិតផលរបស់ប្រទេសថៃ" ។ ការប្រកាសប្រមូលមកវិញនេះ គឺចាប់ផ្តើមបន្ទាប់ពីក្រសួងវិស័យកសិកម្មនិងអ្នកត្រួតពិនិត្យទីផ្សារចំណីបានធ្វើការពិសោធន៏សំណាក់ផលិផលត្រីចំហ៊ុយរបស់ក្រុមហ៊ុន Willis Ocean Inc និងរកឃើញថា ផលិតផលត្រីកាម៉ុងរបស់ក្រុមហ៊ុនមិនត្រូវបានវះយកគ្រឿងក្នុងចេញឱ្យបានត្រឹមត្រូវនោះទេមុនពេលធ្វើការកែឆ្នៃ ។

តាមរយៈការរកឃើញនេះ ត្រីកាម៉ុងចំហ៊ុយរបស់ក្រុមហ៊ុនត្រូវបានហាមខាត់ក្នុងការដាក់លក់នៅតាមទីផ្សារ ដោយសារវាអាចប៉ះពាល់ដល់សុខភាពអ្នកបរិភោព ។ ការបរិភោពត្រីដោយមិនមានការវះយកគ្រឿងក្នុងចេញអាចបង្កឱ្យមានរោគសញ្ញាដូចជាវិលមុខ, ព្រិលភ្នែក, ពិបាកដកដង្ហើម, ភាពទន់ខ្សោយនៃសាច់ដុំផ្សេងទៀត



ត្រីកាម៉ុងចំហ៊ុយដែលត្រូវបានហាមឃាត

និងហើមពោះជាដើម ។ ប៉ុន្តែរហូតមកលពេលមិនមានសេចក្តីរាយការណ៏ណាមួយពីការកើតមានជំងឺទាក់ទងនឹងបញ្ហានេះនៅឡើយនោះទេ ។

យោងតាមការប្រកាស់របស់ការិយាល័យគ្រប់គ្រងចំណីអាហារអតិថិជនដែលបានទិញត្រីកាម៉ុងកញ្ចប់ចំហ៊ុយប្រភេទនេះ ត្រូវបានជុំរុញឱ្យប្រគល់ត្រីដែលបានទិញនោះវិញនៅកន្លែងលក់ដើម្បីដូរយកលុយវិញ ។ បើអតិថិជនមានសំណួរអាចទំនាក់ទំនងទៅកាន់ការិយាល័យការិយាល័យគ្រប់គ្រងចំណីអាហារ និងឱសថតាមរយៈលេខទូរស័ព្ទ 718-386-3053 ៕

Residential
Lending Solutions

Looking to purchase a new home in Massachusetts, New Hampshire or Maine, or exploring the benefits of refinancing? Our team of seasoned Mortgage Officers will guide you through the entire process from initial exploration of financing options to the final closing. With decisions made locally, we are flexible and responsive, and able to create solutions quickly and efficiently.

The Mortgage Center
at Enterprise Bank

978-656-5653 | 877-671-2265

We offer a wide range of programs and services to assist you with your specific financing needs.




Enterprise Bank
CREATE SUCCESS

Get Your FREE Online Pre-Approval Today!

EnterpriseBanking.com/Mortgage

Member FDIC ENT-MKT93S

# បច្ចុប្បន្នភាពនៃពលរដ្ឋខ្មែរនិរទេសចេញពីសហរដ្ឋអាមេរិកទៅកាន់កម្ពុជា

**ដោយ សុខារ័ត្ន កួយ**

**ភ្នំពេញ** -កាលពីពេលថ្មីនេះ ពលរដ្ឋខ្មែរដែលរស់នៅក្នុងទឹកដីអាមេរិកជាច្រើននាក់ ត្រូវបានបញ្ជូនទៅកាន់ប្រទេសកម្ពុជា ហើយតួលេខនៃការធ្វើនិរទេសមានការកើនឡើងជាលំដាប់ជាពិសេសបន្ទាប់ពីការឡើងកាន់ដំណែងជាប្រធានាធិបតេយ្យថ្មីរបស់លោក ដូ ណាល់ត្រាំ ដែលលោកបានកំពុងអនុវត្តន៏នូវការសន្យាក្នុងកំឡុងពេលយុទ្ធនាការបោះឆ្នោតពីគោលនយោបាយអន្តោប្រវេសន៏ ក្នុងហេតុផលដើម្បីសុវត្ថិភាព និងសន្តិសុខប្រទេសអាមេរិក។

លោក ប៊ីល ហឺរ៉ដ (Bill Herod) ទីប្រឹក្សានៃមជ្ឈមណ្ឌលគាំទ្រជនមាតុភូមិនិវត្តន៏សមារណកម្ម (Returnee Integration Support Center) ហៅកាត់ RISC ដែលធ្វើការងារផ្ទាល់ជាមួយជនភៀសខ្លួនបានឱ្យខ្មែរផុសដឹងតាមរយៈសារអេឡិចត្រូនិចថាគិតពីឆ្នាំ ២00២ រហូតមកដល់បច្ចុប្បន្ន



រូបថតលោក សឿន ឆេង ដែលទើបនឹងត្រូវបាននិរទេសកាលពីពេលថ្មីៗ និងជាជាងកាត់សក់មកពីមីនីសូតា កំពុងកាត់សក់ឲ្យលោក ប៊ីល ហឺរ៉េដ ដែលជាអតីតជនជំបូងបង្អស់ ៤ ថ្ងៃបន្ទាប់ពីមកដល់ប្រទេសកម្ពុជា

នេះពលរដ្ឋខ្មែរសរុបទាំងបុរសនិងស្ត្រីចំនួន៥៦៦នាក់ហើយដែលត្រូវបាននិរទេសចេញពីសហរដ្ឋអាមេរិកមកកាន់ប្រទេសកម្ពុជាបានរស់នៅជុំវិញប្រទេសកម្ពុជាដែលភាគច្រើនរស់នៅក្រុងភ្នំពេញនិងខេត្តបាត់ដំបង ហើយមួយចំនួនតូចរស់នៅខេត្តផ្សេងៗទៀត ។

បើតាមការឱ្យដឹងពីលោក ប៊ីល ហឺរ៉ដ ពលរដ្ឋខ្មែរដែលត្រូវបានបញ្ជូនមកកម្ពុជា ជាទូទៅប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនប្រភេទចាប់ពីបទល្មើសតូចតាចរហូតដល់បទឧក្រិដ្ឋហិង្សាធ្ងន់ធ្ងរ ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ភាគច្រើននៃអ្នកដែលត្រូវបញ្ជូនមកមិនបានដឹងថា ការធ្វើនិរទេសនឹងមិនទំនងជាអាចកើតមានឡើងនៅចំពេលនៃការប្រព្រឹត្តបទល្មើសពួកគេនោះទេ។

លោកបានបន្តថា បញ្ហាប្រឈមជាក់ស្តែងសម្រាប់ពលរដ្ឋខ្មែរអាមេរិកដែលត្រូវបាននិរទេសមកកម្ពុជា គឺអ្នកមួយចំនួននិយាយភាសាខ្មែរមិនបានល្អនោះទេ។ ពួកគេជាច្រើនមិនមានការជួយ



អតីតជនភៀសខ្លួនខ្មែរអាមេរិក កំពុងលេង

ពីគ្រួសារនៅអាមេរិក ឬកម្ពុជានោះទេនៅពេលមកដល់។ ពួកគេជាច្រើនបានរៀបការ និងចាប់ផ្តើមគ្រួសារក្នុងប្រទេសកម្ពុជា ។ បន្ទាប់ពីការមកដល់ក្នុងរយៈដំបូង ពួកគេភាគច្រើនរស់តាមបែបជីវភាពធម្មតា ប៉ុន្តែពួកគេតែងតែចង់ចាំ និងនឹកឃើញមិត្តភ័ក្រ្តនិងក្រុមគ្រួសាររបស់ពួកគេដែលនៅសហរដ្ឋអាមេរិក។

ជនភៀសខ្លួនទាំងនោះ ធ្វើរាល់ការងារទាំង

**តទៅទំព័រទី ០៨**




# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហ៊ែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed**
**for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ០៦

## បច្ចុប្បន្នភាពនៃពលរដ្ឋខ្មែរនិរទេស....

អស់ភាគច្រើនបង្រៀនភាសាអង់គ្លេស ឬធ្វើជាអ្នកបកប្រែភាសា, អ្នកបើកបរឡាន, សន្តិសុខ ឬធ្វើការនៅខាងផ្នែកបដិសណ្ឋារកិច្ច ដូចជាអ្នកទទួលទូរស័ព្ទ, អ្នកបំរើតាមហាង, ជាងជួសជុលគ្រឿងអូឌីយ៉ូ, អ្នករត់តាកស៊ី ឬម៉ូតូកងបីជាដើម ហើយមួយចំនួនតូច មានការងារដែលមានមុខតំណែង និងប្រាក់ចំណូលល្អក្នុងក្រុមហ៊ុន ហើយមួយចំនួនទៀត បានចាប់ផ្តើមអាជីវកម្មតូចតាចផ្ទាល់ខ្លួន តែខ្លះទៀតតស៊ូធ្វើការងារខាងផ្នែកសំណង់ដែលទទួលបានប្រាក់ចំណូលទាប។ ទំនេរពីការងារពេលខ្លះ ពួកគេមួយចំនួនជួបជុំគ្នាលេងកីឡាបាល់បោះនិងហូបអាហារជុំគ្នានូវខាងក្រៅ។

ការធ្វើមាតុភូមិនិវត្តន៍ គឺកើតចេញពីកិច្ចព្រមព្រៀងទ្វេរភាគីលើការបង្កើតគណកម្មការចំរុះកម្ពុជាអាមេរិកស្តីពីធ្វើមាតុភូមិនិវត្តន៍ (U.S. -Cambodian Joint Commission on Repatriation) កាលពីឆ្នាំ២០០២ ដោយអនុញ្ញាតឱ្យសហរដ្ឋអាមេរិកនិរទេសពលរដ្ឋខ្មែរដែលរស់នៅស្របច្បាប់ក្នុងទឹកដីសហរដ្ឋអាមេរិកក្រោយពីការអនុវត្តន៍ទោសជាប់ពន្ធនាគារ។

ដោយសារតែកិច្ចព្រមព្រៀងនេះ បានធ្វើឱ្យពលរដ្ឋខ្មែររស់នៅក្នុងសហរដ្ឋអាមេរិកដែលខ្លះកើតក្នុងទឹកដីកម្ពុជា និងខ្លះទៀតមានកំណើតនៅជំរំជនភៀសខ្លួនក្នុងទឹកដីថៃ មានឈ្មោះក្នុងបញ្ជីគោលនយោបាយជនអន្តោប្រវេសន៍សហរដ្ឋអាមេរិក និងត្រូវបាននិរទេសចេញពីសហរដ្ឋអាមេរិក ដោយក្រសួងសន្តិសុខជាតិសហរដ្ឋអាមេរិក (US Department of Homeland Security) តាមរយៈអាជ្ញាធរអន្តោប្រវេសន៍ ដោយសារមានទោសទណ្ឌរឿងប្រព្រឹត្តបទល្មើស និងធ្លាប់ជាប់ពន្ធនាគារ។ ទទ្ទឹមនឹងនេះក៏មានពលរដ្ឋខ្មែរមួយចំនួនកំពុងតែជាប់បណ្តឹងឡើងតុលាអាមេរិកដើម្បីប្រឆាំងទាស់ទៅនឹងការចង់ចាប់បញ្ជូនខ្លួនរបស់ក្រសួងសន្តិសុខជាតិសហរដ្ឋអាមេរិកផងដែរ។

លោក ប៊ីល ហ៊ីរ៉ដ បានលើកឡើងថា គោលនយោបាយនៃការនិរទេសពលរដ្ឋដែលត្រូវបានទទួលស្គាល់ក្នុងទឹកដីអាមេរិកជាជនភៀសខ្លួន ឬបានទទួលសិទ្ធរស់នៅស្រមច្បាប់ជាពលរដ្ឋអចិន្ត្រៃយ៍ហើយនោះគឺជាទង្វើអសីលធម៌ និងហួសហេតុ ប៉ុន្តែវាគឺជាសកម្មភាពស្របច្បាប់មួយ។ ពលរដ្ឋទាំងនេះ តាមបច្ចេកទស គឺជាប្រជាជនកម្ពុជា មិនមែនជាពលដ្ឋរបស់សហរដ្ឋអាមេរិកនោះទេ ហើយស្ថានភាពរបស់ពួកគេគឺជាលទ្ធផលមកពីការបរាជ័យនៃដំណើរការនៃការតាំងទីលំនៅថ្មីរបស់ជនភៀសខ្លួនក្នុងទឹកដីអាមេរិក..។ តាមការរាយការណ៍របស់វិទ្យុអាស៊ីសេរីកាលពីថ្ងៃទី៣០ ខែមិនាតាមរយៈការដកស្រង់សម្តីរបស់អតីតជនភៀសខ្លួនដែលចេញពីសហរដ្ឋអាមេរិកថាការធ្វើមាតុភូមិនិវត្តន៍នេះគឺជាការរំលោភបំពានសិទ្ធិពួកគេ។

ទាក់ទងនឹងកិច្ចព្រមព្រៀងនេះផងដែរ រដ្ឋាភិបាលកម្ពុជាបង្ហាញប្រតិកម្មជំទាស់ទៅនឹងវិធានការបញ្ជូនខ្លួនពលរដ្ឋកម្ពុជានេះ ហើយកាលពីចុងខែ តុលា២០១៦ ក្រសួងការបរទេសប្រទេសកម្ពុជាក៏បានស្នើរសុំស្ថានទូតអាមេរិកប្រចាំក្រុងភ្នំពេញឱ្យធ្វើការពន្យារពេលជាបណ្តោះអាសន្ននូវកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍ឆ្នាំ២០០២ ហើយបន្ទាប់មកភាគីកម្ពុជាក៏បានបញ្ចប់ពង្រៀងសំណើរវិសោធនកម្មកិច្ចព្រមព្រៀងបញ្ជូនខ្លួនរួចរាល់ហើយនឹងលើកសំណើរសុំចចារឡើងវិញជាមួយភាគីអាមេរិក។ លោក ប៊ីល ហ៊ីរ៉ដ ថា ខ្ញុំមិនរំពឹងថាសហរដ្ឋអាមេរិកនឹងកែសម្រួលកិច្ចព្រមព្រៀងបញ្ជូនខ្លួននេះនោះទេ...។

លោកបានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាបានចេញបែបបទធ្វើដំណើរដល់ជនភៀសខ្លួនខ្មែរអាមេរិកទាំង ៥៥៦ នាក់រួចរាល់ចាប់តាំងពីឆ្នាំ២០០២ ហើយរដ្ឋាភិបាលកម្ពុជា ក៏បានបរិសេដចំពោះករណីនៃការបញ្ជូនខ្លួនមួយចំនួនកាលពីពេលកន្លងទៅដោយយោងតាមកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍រវាងកម្ពុជា និងអាមេរិកនេះដែលអនុញ្ញាតឱ្យធ្វើការពិនិត្យករណីមួយម្តងៗផ្អែកលើបុព្វហេតុមនុស្សធម៌ និងមេត្តាករុណា។ រដ្ឋាភិបាលហាក់បីដូចជាកំពុងតែប្រើប្រាស់ប្រការនេះកាន់តែខ្លាំងជាងមុន ដូច្នេះយើងគួរតែជំរុញ និងគាំទ្រចំពោះកិច្ចខំប្រឹងប្រែងនេះ ជាពិសេសដោយសាររដ្ឋបាលអាមេរិកបច្ចុប្បន្ននេះ ហាក់ដូចជាទំនោរពង្រើកការអនុវត្តន៍ផ្អែកនៃបទល្មើសដែលអាចនិរទេស។

សូមបញ្ជាក់ថា មជ្ឈមណ្ឌលគាំទ្រជនមាតុភូមិនិវត្តន៍សមារណកម្ម (RISC) ជាអង្គការមិនមែនរដ្ឋាភិបាលបង្កើតឡើងក្នុងឆ្នាំ២០០២ ដើម្បីឆ្លើយតមទៅនឹងការធ្វើមាតុភូមិនិវត្តន៍ដំបូងនៃពលរដ្ឋខ្មែរអាមេរិក និងមានអ្នកបំរើការងារចំនួន ៤នាក់។ រាល់ការមកដល់របស់ជនភៀសខ្លួនខ្មែរពីអាមេរិកអង្គការប្រជនឹងជួបជាមួយពួកគេនៅពេលមកដល់ និងជួយឱ្យជួមជាមួយនឹងសាច់ញាតិដែលពួកគេមាន។ ប្រសិនបើមិនមានសាច់ញាតិនោះទេ RISC នឹងផ្តល់ការស្នាក់នៅជាបណ្តោះអាសន្ន និងជួយតំរង់ទិស និងសម្រួលក្នុងការទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណសំខាន់ៗ, ស្វែងរកការងារធ្វើ និងផ្ទះស្នាក់នៅអចិន្ត្រៃយ៍ ព្រមទាំងជួយការសេវាសង្គ្រោះបន្ទាន់បើចាំបាច់៕




# ក្រុមហ៊ុន Samsung ចេញផលិតផលម៉ូនីទ័រកោងវែងប្រភេទថ្មី

**ប្រែសម្រួលដោយខ្មែរផុសស.រ.អា**

ក្រុមហ៊ុនអ៊ីលិចត្រូនិច Samsung បានធ្វើការដាក់បង្ហាញផ្លូវការនូវផលិតផលម៉ូនីទ័ររាងវែងកោងថ្មីចំនួនពីប្រភេទ CHG90 និង CHG70 ដែលមានកិរិតបច្ចេកទេសរូបភាព HDR ខ្ពស់ កាលពីថ្ងៃសៅរ៍ ទី១០ ខែមិថុនានេះ។ ម៉ូលដែលថ្មីចំនួនបី ទើបតែបានប្រកាសដែលមានផលិតផលម៉ូនីទ័រប្រភេទ Samsung CHG90 លិចធ្លោជាងគេបំផុត។ ទំហំអេក្រង់នៃម៉ូដែលទាំងបីមានដូចជា ទំហំ 27inch, 32 inch និងអេក្រង់ QLED 49inch ។

បើទោះបីជាទីផ្សារចំបងសម្រាប់ផលិតផលថ្មីនេះ គឺអ្នកនិយមការលេងហ្គេមយ៉ាងណាក៏ដោយក្រុមហ៊ុនបាននិយាយថា ម៉ូនីទ័រប្រភេទនេះគ្រប់ដណ្តប់ 95% នៃកិរិតពិណ DCI-P3 ដែលវាគឺជាជំរើសដ៏ល្អមិនត្រឹមតែសម្រាប់អ្នកថតរូបប៉ុណ្ណោះទេ ថែមទាំងសម្រាប់អ្នកកាត់តវីដេអូផងដែរ។

ដើម្បីកាត់បន្ថយការព្រិល ឬមិនច្បាស់នៃអាក្រងម៉ូនីទ័រ (Monitor Blur), ក្រុមហ៊ុន Samsung បង្កើតឱ្យមាន Refresh rate ដល់ទៅ 144Hz ដោយមានពេលវេលាឆ្លើយតប ១មស និងមានមុខងារស្កេនបួន។ ដោយមានបន្ថែម QLED វានឹងផ្តល់ឱ្យអ្នកប្រើប្រាស់នូវពន្លឺអេក្រងកាន់តែច្បាស់ជាងម៉ូនីទ័រអេក្រង់ OLED ទៅទៀត។

ម៉ូដែលដែលមានអេក្រង់តូចបំផុត គឺមានអេក្រង Quad HD ដែលមានទំហំ 2560 x 1140Resolution ហើយម៉ូដែលធំជាងគេមានមុខងារអនុញ្ញាតឱ្យអ្នកប្រើប្រាស់កំណត់ចែករូប ២ក្នុងអេក្រងទេមួយ ហើយបំណែងចែកនិមួយៗ បង្ហាញរូបទំហំ UHD: 3840 × 1080 កម្រិត Full HD ។

លោកអ្នកអាចរកទិញម៉ូដែល 27Inch ក្នុងតំលៃ $599, ម៉ូដែល 32Inch តំលៃ $ 699 បានតាមរយៈ online ។ សម្រាប់អ្នកលេងហ្គេមដែលគិតថា ទំហំអេក្រង់កាន់តែធំគឺកាន់តែល្អប្រសើរ នោះឬក៏មិនចង់ងាកមើនច្រើនជាមួយនឹងម៉ូនីទ័រ ២នោះ លោកអ្នកអាចជ្រើសយកម៉ូនីទ័រ 49Inch ។ វាតំលៃ $ 1,499 ហើយលោកអ្នកអាចធ្វើការបញ្ជាទិញជាមុនតាមរយៈក្រុមហ៊ុន Amazon ដោយដឹកជញ្ជូនទៅដល់លោកអ្នកនៅថ្ងៃទី ៣០ ខែមិថុនា៕



Samsung 32" CHG70



Samsung CHG90 49" Screen




# តម្រឹមធ្មេញដោយមិនយកថ្លៃ

ប្រសិនបើលោកអ្នកឬគ្រួសារ មានអាយុ២១ឆ្នាំ ឬក្មេងជាង សូមទូរស័ព្ទមកយើងនៅថ្ងៃនេះ
ដើម្បីរកមើលថាតើលោកអ្នកមានសិទ្ធនឹងទទួលបាននូវ "ប្រដាប់តម្រឹមធ្មេញ"ដោយ មិនចំណាយប្រាក់
ឬទេនៅពេលលោកអ្នកមាន"ម៉ាសហ៊ែល"? លោកអ្នកអាចនឹងទទួលសំណងរហូតដល់៤,៣០០ដុល្លា
សម្រាប់ដាក់"ប្រដាប់តម្រឹមធ្មេញ"ទៅតាមសេចក្តីត្រូវការរបស់អ្នក។

The BRACES PLACE
វេជ្ជបណ្ឌិត មូហាប់ រីសកាឡា DDS MSD

## តើយើងធ្វើអ្វីខ្លះ?

ដាក់ធ្មេញដោយដែក * ដោយមាស * ដោយ"អិនវីសាឡាញ" * ដោយចាន

## អ្វីដែលធ្វើឱ្យយើងប្រសើរជាននោះ?

- ឆ្លុះមើលបន្ថែម នឹង ជួបគ្រូពេទ្យ
- យើងទទួលយក"ម៉ាសហ៊ែល" នឹង "អិនស្វីន"ផ្សេងៗទៀត
- បង់ប្រាក់កក់មុនតិចបំផុត នឹងមានវិធីបង់ប្រាក់រំលោះប្រចាំខែសម្រាប់អ្នកដែលគ្មាន"អិនស្វិន" សូមទូរស័ព្ទ ឬក៏មកកន្លែងដែលស្រួលរករបស់យើង

710 Chelmsford St. Lowell, MA 01851
(978)- 454 - 0774 (មានអ្នកនិយាយភាសាខ្មែរ)
ដើម្បីបានព័តិមានបន្ថែម, សូមចូលទៅ"វេបសាយ"យើង: www.bracesplaces.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការរាប់សន្លឹកឆ្នោតឡើងវិញ ធ្វើឱ្យ CNRP ឈ្នះពីរឃុំទៀត យ៉ាងប្រកៀកប្រកិត

**ដោយ បែន សុខហ៊ាន | ថ្ងៃព្រហស្បតិ៍ ទី១៥ ខែមិថុនា ឆ្នាំ២០១៧**

ការរាប់សន្លឹកឆ្នោតឡើងវិញកាលពីម្សិលមិញ គណបក្សសង្គ្រោះជាតិឈ្នះពីរឃុំបន្ថែមទៀត គឺឃុំមួយក្នុងខេត្តបាត់ដំបង និងឃុំមួយទៀតក្នុងខេត្តកំពង់ធំ គឺមួយថ្ងៃបន្ទាប់ពីឃុំសង្កាត់ដំបូងដំបូងនៃឃុំសង្កាត់ចំនួន៤០ដែលមានភាពចម្រូងចម្រាសនៅក្នុងការបោះឆ្នោតឃុំ សង្កាត់កាលពីថ្ងៃទី៤ ខែមិថុនាបានទៅលើគណបក្សប្រជាជនកម្ពុជានោះ។

បន្ទាប់ពីការរាប់ពេញមួយថ្ងៃ លោក ហង្ស ពុទ្ធា អ្នកនាំពាក្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសកាលពីយប់មិញថា គណបក្សសង្គ្រោះជាតិបានឈ្នះត្រឹមតែពីរសំឡេងប៉ុណ្ណោះ ក្នុងឃុំក្លែង ខេត្តកំពង់ធំ។ ពីដំបូងគណបក្សកាន់អំណាចបានឈ្នះតំណែងមេឃុំតែមួយសំឡេងប៉ុណ្ណោះ មុនពេលគណបក្សប្រឆាំងបានប្តឹងទៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តដែលបានបង្វែរការរាប់សន្លឹកឆ្នោតឡើងវិញនេះទៅគ.ជ.ប។

នៅក្នុងឃុំបឹងប្រាំក្នុងខេត្តបាត់ដំបងគណបក្សសង្គ្រោះជាតិឈ្នះគណបក្សប្រជាជនកម្ពុជា៥៩សំឡេង ដែលពីដំបូងឈ្នះ២៣សំឡេង។

ការទទួលបាននេះកើតមានឡើងបន្ទាប់ពីការរាប់សន្លឹកឆ្នោតឡើងវិញរយៈពេលពីរថ្ងៃក្នុងឃុំដូង ខេតតស្វាយរៀង ដែលបានទៅគណបក្សប្រជាជនកម្ពុជាត្រឹមពីរសំឡេងកាលពីថ្ងៃអង្គារបន្ទាប់ពីមានវិវាទដ៏ក្តៅគគុករវាងតំណាងគណបក្សធំៗទាំងពីរនេះកាលពីថ្ងៃមុន។

លោក ហង្ស ពុទ្ធា បានចាត់ទុកដំណើរការរាប់សន្លឹកឆ្នោតឡើងវិញកាលពីម្សិលមិញថា "មានតម្លាភាព" ខណៈដែលអ្នកយកព័ត៌មាននៅក្នុងបន្ទប់សន្លឹកឆ្នោតសង្កេតឃើញថា មានបរិយាកាសស្ងប់ស្ងាត់ជាងវិវាទកាលពីថ្ងៃច័ន្ទ។

លោក ហង្ស ពុទ្ធា បានមានប្រសាសន៍ថា "បើយើងដាក់ចិត្តជាអ្នកប្រកួតហើយ រឿងចាញ់ឈ្នះជារឿងធម្មតា"។

លោក ងួន កុលបុត្រតំណាងគណបក្សប្រជាជនកម្ពុជាដែលមានវត្តមាននៅការរាប់សន្លឹកឆ្នោតកាលពីម្សិលមិញ បានមានប្រសាសន៍ថា លោកទទួលយកលទ្ធផលនេះ។ លោកបានថ្លែងថា "សម្រាប់ខ្លួនខ្ញុំផ្ទាល់ខ្ញុំគិតថា ល្អត្រឹមត្រូវ ពីព្រោះវាបង្ហាញពីឆន្ទៈទាំងអស់គ្នា"។ លោកបានបន្ថែមថា "យើងមានទាំងតំណាងអង្គការសង្គមស៊ីវិលយើងមានទាំងតំណាងគណបក្សនយោបាយពាក់ព័ន្ធ។ ខ្ញុំឃើញថា វាប្រព្រឹត្តទៅល្អហើយ"។

លោក ហង្ស ពុទ្ធា បានថ្លែងថា រហូតមកទល់ពេលនេះ គ.ជ.ប ទទួលបាន៤៧ បណ្តឹងចាប់តាំងពីថ្ងៃបោះឆ្នោតមក ហើយ២៣បណ្តឹងត្រូវបានដោះស្រាយរួចហើយ។ លោកបានបន្ថែមថា បណ្តឹងមួយចំនួនទៀតត្រូវបានច្រានចោល។

លោកស្រី ម៉េង សុភារី ប្រធានកិច្ចការបោះឆ្នោតនិងនីតិកម្មរបស់គណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា គណបក្សលោកស្រីបានដាក់បណ្តឹងសរុប៣២បណ្តឹងទៅគ.ជ.ប រួមទាំងសំណើចំនួន៣០ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញក្នុងឃុំសង្កាត់ក្នុងខេត្តចំនួន១៥។

លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា លោកទុកចិត្តលើការរាប់សន្លឹកឆ្នោតចុងក្រោយនេះ ប៉ុន្តែលោកបាននិយាយឡើងវិញពីការរិះគន់របស់អ្នកសង្កេតការណ៍ឯករាជ្យមួយចំនួនដែលថា បរិយាកាសមុនការបោះឆ្នោតបានធ្វើឱ្យប៉ះពាល់ដល់ដំណើរការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ។

ដោយសំដៅដល់លោក សម រង្ស៊ី ដែល បានលាលែងពីតំណែងកាលពីខែកុម្ភៈ មុនពេលការអនុម័តធ្វើវិសោធនកម្មដ៏ចម្រូងចម្រាសចំពោះច្បាប់ស្តីពីគណបក្សនយោបាយនោះ លោកបានថ្លែងថា "ខ្ញុំបាននិយាយហើយថា សេរី និងយុត្តិធម៌វាមានពីរ...។ គ.ជ.ប ដំណើរការទៅល្អជាងមុន ប៉ុន្តែនៅមានបរិយាកាសនៃការបំភិតបំភ័យគំរាមកំហែង និងគាបសង្កត់ឯកឧត្តមអតីតប្រធានមិនឱ្យចូលរួមជាមួយយើងដដែល" ៕ **សារុន**



សន្លឹកឆ្នោតចេញពីការបោះឆ្នោតឃុំ សង្កាត់កាលពីថ្ងៃទី៤ ខែមិថុនា ត្រូវបានត្រួតពិនិត្យអំឡុងពេលរាប់សន្លឹកឆ្នោតឡើងវិញនៅទីស្នាក់ការកណ្តាលរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅក្នុងរាជធានីភ្នំពេញកាលពីម្សិលមិញ។ រូបថតៈស៊ីវចាន់ណា,ឌឹខេមបូឌាដេលី

# BALLOT RECOUNTS NARROWLY SWING TWO COMMUNES TO CNRP

**by Ben Sokhean | June 15, 2017**

Ballot recounts on Wednesday secured the opposition CNRP two more commune wins-one each in Battambang and Kompong Thom provinces-a day after the first of 40 contested communes in the June 4 local elections swung to the CPP.

After a full day of counting, National Election Committee (NEC) spokesman Hang Puthea announced last night that the CNRP had won by just two votes in Kompong Thom province's Kleng commune. The ruling party had initially won the commune chief spot by one vote before the opposition appealed to the provincial election committee, which referred a recount to the NEC.



In Battambang province's Boeng Bram commune, the CNRP won 59 more votes than the CPP, which originally had an edge of 23.

The gains followed a two-day recount of votes in SvayRieng province's Doung commune, which went to the CPP by two votes on Tuesday after heated arguments between the two major parties' representatives the previous day.

Mr. Puthea described Wednesday's recounting process as "transparent," while reporters inside the counting room observed a calmer atmosphere than Monday's rowdiness. "If you are a competitor, winning or losing is normal," Mr. Puthea said.

NguonKolboth, a CPP representative who was at the recount on Wednesday, said he accepted the results. "For me, I think it's correct, because it shows the will of the people," he said.

"We have representatives of civil society; we have representatives of political parties. I see it happened well," he added.

Mr. Puthea said the NEC had so far received 47 complaints since Election Day, 23 of which have been resolved. Some complaints had been rejected, he added.

Meng Sopheary, the CNRP's head of electoral and legislative affairs, said her party had filed a total of 32 complaints to the NEC, including 30 requests for recounts in communes across 15 provinces.

CNRP spokesman Yim Sovann said he trusted the final ballot counts, but he reiterated criticism from some independent observers that the pre-elections climate had undermined the democratic nature of the vote.

"I already said the words 'free and fair' are two [different] things…. The NEC is processing better, but there is still a situation of intimidation, threats and pressure on our former party president," he said, referring to Sam Rainsy, who resigned in February before the passage of controversial amendments to the Law on Political Parties.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# មេធាវីការពារក្តីឱ្យ ខៀវ សំផន បន្ត ចំអកឱ្យសាលាក្តីខ្មែរក្រហម

**ដោយ ហ្គូច រ៉ាយត៍ | ថ្ងៃពុធ ទី២១ ខែមិថុនា ឆ្នាំ២០១៧**

ក្រុមមេធាវីការពារក្តីឱ្យ ខៀវ សំផន បាន បន្តចំអកឱ្យសាលាក្តីខ្មែរក្រហមកាលពីម្សិលមិញ ដោយចោទប្រកាន់អង្គជំនុំជម្រះនេះថា មិនសូវចាប់អារម្មណ៍នៅក្នុងការធានាការបើកសវនាការដោយយុត្តិធម៌ហើយបានប្រកាសថា សាលាក្តីនេះសម្រេចបេសកកម្មរបស់ខ្លួនរួចហើយនៅក្នុងការផ្តន្ទាទោសឱ្យប្រមុខរដ្ឋនៅសម័យខ្មែរក្រហមរូបនេះជាប់ពន្ធនាគារអស់មួយជីវិត។

លោកស្រី អានតា ហ្គីស្សេ (Anta Guisse) មេធាវីការពារក្តីអន្តរជាតិបានលើកឡើងថា "លោក ខៀវ សំផន នឹងទទួលមរណភាពនៅក្នុងពន្ធនាគារ"។ លោកស្រីលើកឡើងយ៉ាងដូច្នេះខណៈពេលលោកស្រីចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសវនាការដែលមានរយៈពេល២ឆ្នាំកន្លះនេះ ។

មេធាវីជនជាតិបារាំងរូបនេះបានប្រកាសនៅក្នុងសេចក្តីសន្និដ្ឋានដែលមានគោលដៅលើអង្គចៅក្រមថា "គាត់នឹងទទួលមរណភាពនៅក្នុងពន្ធនាគារ ហើយគាត់ក៏ដឹងខ្លួនឯងដែរ។ មេធាវីការពារក្តីឱ្យគាត់ក៏ដឹងដែរ ហើយអ្នកក៏ដឹងដូចគ្នា"។

លោកស្រីបានមានប្រសាសន៍បន្ថែមថា "បេសកកម្មសម្រេចហើយ។ អ្នកបានផ្តន្ទាទោសឱ្យគាត់ជាប់ទោសអស់មួយជីវិត នោះហើយ គឺជាគោលដៅរបស់សវនាការជាប្រវត្តិសាស្ត្រមួយនេះ គឺផ្តន្ទាទោសឱ្យលោក ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិត"។

ខៀវ សំផន អាយុ៨៥ឆ្នាំ និងបងធំទី២នៅរបបខ្មែរក្រហមគឺ នួន ជា ដែលមានអាយុ៩០ឆ្នាំ ជិតឈានដល់ពេលបញ្ចប់ការបើកសវនាការលើកទី២ហើយ ពីបទឧក្រិដ្ឋយ៉ាងច្រើនដែលប្រឆាំងនឹងមនុស្សជាតិរួមទាំងបទប្រល័យពូជសាសន៍ផង។

កាលពីឆ្នាំមុនពួកគាត់បានចាញ់នៅក្នុងការប្តឹងទាស់នឹងការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតនៅក្នុងសវនាការលើកទី១ ពីបទឧក្រិដ្ឋដែលផ្តោតយ៉ាងខ្លាំងលើការជម្លៀសប្រជាពលរដ្ឋចេញពីក្រុងភ្នំពេញ បន្ទាប់ពីក្រុមកុម្មុយនីស្តជ្រុលនិយមមួយនេះឡើងកាន់អំណាចនៅក្នុងខែមេសា ឆ្នាំ១៩៧៥។

ការផ្តន្ទាទោសលើកដំបូងបានសម្រេចតាមបំណងនៃសាលក្រមផ្តន្ទាទោសរបស់អយ្យការ ជនរងគ្រោះដែលគេហៅថា ដើមបណ្តឹងរដ្ឋប្បវេណី និងម្ចាស់ជំនួយ នេះបើយោងតាមការលើកឡើងរបស់លោកស្រី អានតា ហ្គីស្សេ ដោយគូសបញ្ជាក់ថា "បេសកកម្មទី២"របស់អង្គចៅក្រម គឺត្រូវប្រកាសសាលក្រមផ្តន្ទាទោសមួយទៀតនៅក្នុងសវនាការលើកទី២។

លោកស្រីបានមានប្រសាសន៍ថា "លោកប្រធានខ្ញុំជឿជាក់ថា ចាប់ពីថ្ងៃនេះទៅរហូតដល់ប៉ុន្មានខែទៀតពេលមានការចេញសាលក្រមថ្មី



នឹងមានការលើកសរសើរជាថ្មីនៅក្នុងដំណើរការរបស់សាលាក្តីនេះ"។

លោកស្រីបានបន្ថែមថា "នឹងមានគោលដៅផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតថ្មីមួយទៀត។ ហើយនឹងមានការអបអរសាទរដូចនៅក្នុងសំណុំរឿង002,០១ដែលទទួលបានជ័យជម្នះនៅក្នុងការតស៊ូប្រឆាំងនឹងនិទណ្ឌភាពដែរ"។

លោកស្រី អានតា ហ្គីស្សេ ក៏បានលើកឡើងផងដែរថា សវនាការនេះមានភាពលម្អៀង ហើយបានចោទសួរថា តើវាមានតម្លៃដែរ ឬទេក្នុងការធ្វើជាគំរូសម្រាប់កម្ពុជា និងពិភពលោក។

លោកស្រីបានចោទប្រកាន់សាលាក្តីនេះថា មិនសូវចាប់អារម្មណ៍នៅក្នុងគោលការណ៍ច្បាប់មូលដ្ឋាន ឬនៅក្នុងការការពារសិទ្ធិសម្រាប់សវនាការប្រកបដោយភាពយុត្តិធម៌មួយឡើយ។ លោកស្រីបានបន្ថែមថា មានការលេចឡើងនូវ "ស្ថានភាពមិនគួរឱ្យជឿទុកចិត្ត"ដែលការពិភាក្សាស៊ីជម្រៅពាក់ព័ន្ធនឹងច្បាប់ត្រូវបានចាត់ទុកថា មាន "ភាពចម្លែក"នៅក្នុងសាលសវនាការ។

លោកស្រីបានថ្លែងថា "ហេតុអ្វីយើងត្រូវខ្វាយខ្វល់ម្តងទៀតដោយសារសំណួរបច្ចេកទេសទាំងនេះ? នោះគឺជាអ្វីដែលអ្នកអាចនឹងសួរ"។

តទៅទំព័រទី ១២

# KHIEU SAMPHAN DEFENSE MOCKS COURT, 'ARROGANT' PROSECUTION

**by George Wright | June 21, 2017**

KhieuSamphan's defense team went on the attack against the Khmer Rouge tribunal on Tuesday, accusing the Trial Chamber of showing little interest in ensuring a fair trial and proclaiming that it had already accomplished its mission in securing a life sentence for the regime's head of state.

"Mr. KhieuSamphan is going to die in jail," international defense lawyer Anta Guisse said as she began her closing statement in the two-and-a-half-year trial.

"He's going to die in jail and he knows that. His defense knows that as well. You know it as well," the French lawyer declared in the statement aimed at the judges.

"Mission accomplished. You sentenced him to life and that was the objective of this historic trial-sentencing Mr. KhieuSamphan to life."

Both KhieuSamphan, 85, and the Khmer Rouge second-in-command Nuon Chea, 90, are nearing the end of their second trial for widespread crimes against humanity, including genocide.

Last year, they lost their appeals to the life sentences handed down in a first trial for crimes heavily focused on the evacuation of Phnom Penh after the ultra-communists took power in April 1975.

The first sentence had quenched the thirst for a guilty verdict from the prosecution, victims known as civil parties and donors, Ms. Guisse said, scornfully pointing out the judges' "second mission" was to deliver another guilty verdict in the second trial.

"I do not doubt, Mr. President, that between now and a few months from today, when a new verdict will be issued, there will be new accolades in the corridors of this tribunal to congratulate ourselves," she said.

"There will have been a Holy Grail of a new life sentence. We will congratulate ourselves like in Case 002 /01 of this victory in the struggle against impunity."

Ms. Guisse also said the trial was biased and questioned whether it was worthy of being a model for Cambodia and the world.

She accused the court of having little interest in basic principles of law or defending the right to a fair trial, adding that an "incredible situation" had arisen where in-depth discussions of law were considered "almost odd" in the courtroom.

"Why are we being bothered again with these technical questions? That's what you may ask," Ms. Guisse said.

She added, in a mocking tone, "And after all, these Khmer Rouge have a bit of nerve, don't you think? Were there any fair trials under [Democratic Kampuchea]? They should already be happy to have lawyers represent them?"

The prosecution had become "arrogant," due to its belief that the burden of proof had been reversed, Ms. Guisse claimed.

The prosecutors "have the certainty that no matter what they do…their case is necessarily going to prevail," she said, claiming that their closing statements were as if "the proceedings that took place before this courtroom never took place."

Ms. Guisse cited examples of events-including the treatment of the Khmer Krom and incursions into Vietnamese territory by Khmer Rouge troops-presented by the prosecution and civil parties that fell outside the scope of the charges against KhieuSamphan.

It "might be shocking for some of you, but KhieuSamphan is not being tried for everything that happened in Cambodia between 1975 and 1979," she said.

The closing statement by KhieuSamphan's defense team concludes today.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីឯកសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# អង្គការឃ្លាំមើលសិទ្ធិមនុស្សរិះគន់យ៉ាងខ្លាំងថា ការបោះឆ្នោត "មិនសេរី និងមិនត្រឹមត្រូវយុត្តិធម៌"

**ដោយ ឆន ភារុណ | ថ្ងៃពុធ ទី១៤ ខែមិថុនា ឆ្នាំ២០១៧**

កាលពីម្សិលមិញអង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) ដែលជាអ្នករិះគន់រដ្ឋាភិបាលខ្លាំងបំផុតជាយូរមកហើយ បានថ្កោលទោសការបោះឆ្នោតឃុំ សង្កាត់កាលពីថ្ងៃទី៤ ខែ មិថុនា ថា "មិនសេរី និងមិនត្រឹមត្រូវយុត្តិធម៌" ហើយបានអំពាវនាវឱ្យធ្វើកំណែទម្រង់ជាបន្ទាន់ដើម្បីការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំក្រោយ ។

ទន្ទឹមនឹងយល់ស្របតាមទស្សនៈរបស់អ្នកសង្កេតការណ៍អន្តរជាតិផ្សេងទៀតរួមមានទាំងសហភាពអឺរ៉ុប និងស្ថានទូតអាមេរិកប្រចាំនៅរាជធានីភ្នំពេញផង ដែលយល់ឃើញថា ថ្ងៃបោះឆ្នោតប្រព្រឹត្តទៅដោយ "សន្តិវិធី" អង្គការដែលមានមូលដ្ឋាននៅក្នុងទីក្រុងញូវយ៉កមួយនេះបានរិះគន់យ៉ាងខ្លាំងៗចំពោះបរិយាកាសក្រោយការបោះឆ្នោត ដោយនិយាយថា ការបោះឆ្នោតនេះ "បានធ្វើឡើងក្នុងបរិយាកាសគំរាមកំហែងដល់សេរីភាពបញ្ចេញមតិ និងការចូលរួមពិតប្រាកដ" ។

អង្គការនេះបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍ថា? ការគំរាមកំហែងពីសំណាក់លោក-នាយករដ្ឋមន្ត្រីហ៊ុនសែនថានឹងមានសង្គ្រាមកើតឡើងប្រសិនបើគណបក្សកាន់អំណាចចាញ់ឆ្នោត "តុលាការគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា" ដែលចាប់គូប្រជែងខាងនយោបាយ និងមន្ត្រីអង្គការសង្គមស៊ីវិលដែលប្រឆាំងគណបក្សកាន់អំណាច ដាក់ពន្ធនាគារ ប្រព័ន្ធផ្សព្វផ្សាយមានភាពលម្អៀង និងដំណើរការបោះឆ្នោត "ដែលមានគុណវិបត្តិជាមូលដ្ឋាន" បានធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យ ។

លោក ប្រេដ អាដាម នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍ដដែលនេះថា "បើគ្មានស្តង់ដារផង តើការបោះឆ្នោតអាចចាត់ទុកបានថា សេរី និងត្រឹមត្រូវយុត្តិធម៌បានយ៉ាងម៉េចនៅពេលមានបញ្ហាទាំងនេះកើតឡើង" ។

វាបានឆ្លុះបញ្ចាំងពីក្តីបារម្ភរបស់អ្នកសង្កេតការណ៍ឯករាជ្យមួយចំនួននៅមុនថ្ងៃបោះឆ្នោត ប៉ុន្តែខុសគ្នាស្រឡះពីស្ថានទូតអាមេរិក ដែលបានសរសើរការបោះឆ្នោតឃុំ សង្កាត់ កាលពីសប្តាហ៍មុននេះថា ជា "ព្រឹត្តិការណ៍ដ៏សំខាន់នៅក្នុងការបន្តអភិវឌ្ឍប្រកបដោយលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា" ។

លោក ប្រេដ អាដាម ត្រូវបានដកស្រង់ប្រសាសន៍ថា ដោយសារតែគណបក្សធំៗទាំងពីរទទួលបានសំឡេងឆ្នោតប្រជិតប្រសងគ្នា វា "ច្បាស់ណាស់ថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០១៨ ខាងមុខនឹងមានការប្រកួតប្រជែងគ្នាយ៉ាងស្វិតស្វាញជាថ្មីម្តងទៀត ជាហេតុធ្វើឱ្យវាកាន់តែមានសារៈសំខាន់ជាងពេលណាទាំងអស់ដែលត្រូវធ្វើកំណែទម្រង់មូលដ្ឋានជាបន្ទាន់" ។

លោកបានលើកឡើងបន្តថា "បើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រធ្វើឡើងនៅឆ្នាំក្រោយក្រោមស្ថានភាពដូចគ្នានេះ វានឹងមិនត្រូវបានចាត់ទុកថាសេរី និងត្រឹមត្រូវយុត្តិធម៌នោះទេ" ។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា លោកបានដឹងពីសេចក្តីថ្លែងការណ៍នេះ ប៉ុន្តែបានតបទៅវិញថា ស្ថានទូតអាមេរិក និងសហភាពអឺរ៉ុបបានវាយតម្លៃថា ការបោះឆ្នោតនេះមានលក្ខណៈសេរីត្រឹមត្រូវយុត្តិធម៌ដោយសន្តិវិធី និងប្រព្រឹត្តទៅដោយរលូន" ។

លោកបានបន្ថែមថា "ខ្ញុំសុំសួរបន្តិច... តើលោក ប្រេដ អាដាម ឆ្កួតឬក៏ពិភពលោកឆ្កួត? តើស្ថានទូតអាមេរិកឆ្កួត?" ៕ **សុខុម**

Continued from page 01

## HUMAN RIGHTS WATCH...

in a threatening environment hostile to free speech and genuine participation."

Prime Minister Hun Sen's threats of war if the ruling party lost, "CPP-controlled courts" that imprison the ruling party's opponents, biased media and a "fundamentally flawed" electoral process undermined the vote, the statement added.

"Under no standards anywhere can an election be deemed fair or free when these kinds of problems exist," HRW Asia director Brad Adams was quoted as saying.

It mirrored concerns from other observers about the run-up to polling day, but went far beyond the U.S. Embassy, which hailed the commune elections last week as "an important milestone in Cambodia's continued democratic development."

It was "clear that the upcoming 2018 national elections will again be tightly contested, making it more important than ever to carry out urgent fundamental reforms," Mr. Adams was quoted as saying. "[I]f national elections take place next year under the same conditions they will not be considered free and fair."

CPP spokesman SokEysan said he was aware of the statement, but countered that "the U.S. Embassy and E.U. evaluated that the election was free and fair, peaceful and went smoothly."

"Let me ask…. Is Brad Adams crazy or is the world crazy? Is the U.S. Embassy crazy?"

## តមកពីទំព័រទី ១១ មេធាវីការពារក្តី ខៀវ សំផន...

លោកស្រីបាននិយាយបន្ថែមនៅក្នុងសំដីបែបចំអកថា "បន្ថែមពីលើនេះទៅទៀតសាលាក្តីខ្មែរក្រហមនេះមានការខ្វាយខ្វល់បន្តិចតើអ្នកមានគិតអ៊ីចឹងអត់? តើមានសវនាការប្រកបដោយភាពយុត្តិធម៌ណាមួយទេ ក្រោមរបបឱ្យកម្ពុជាប្រជាធិបតេយ្យ ពួកគាត់គួរតែសប្បាយចិត្តទៅដែលមានមេធាវីតំណាងពួកគាត់នោះ?" ។ លោកស្រី អានតា ហ្គីស្សេ បានអះអាងថា អយ្យការមានភាព "ក្រអឺតក្រទម"ដោយសារមានជំនឿថា បន្ទុកភ័ស្តុតាងត្រូវបានកែប្រែ ។

លោកស្រីមានប្រសាសន៍ថា "អយ្យការមានភាពប្រាកដប្រជាថា មិនថា ពួកគេធ្វើអ្វីនោះទេ ដាច់ខាតសំណុំរឿងរបស់ពួកគេត្រូវតែទទួលបានជ័យជម្នះ" ។ លោកស្រីបានអះអាងថា សវនាការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ពួកគេមើទៅ "ហាក់បីដូចជាមាននីតិវិធីនៅចំពោះមុខសាលសវនាការតាមពិតមិនមាននោះទេ" ។

លោកស្រី អានតា ហ្គីស្សេ បានលើកឡើងពីឧទាហរណ៍នៃស្ថានការណ៍បង្ហាញដោយអយ្យការ និងដើមបណ្តឹងរដ្ឋប្បវេណីដែលហួសពីទំហំនៃការចោទប្រកាន់លើ ខៀវ សំផន ក្នុងនោះរួមមានការប្រព្រឹត្តលើខ្មែរក្រោម និងការលុកលុយចូលទឹកដីវៀតណាមដោយទាហានខ្មែរក្រហមជាដើម ។

លោកស្រីបានថ្លែងថាវា "ប្រហែលជាធ្វើឱ្យអ្នកខ្លះមានការតក់ស្លុត ប៉ុន្តែ ខៀវ សំផន មិនកំពុងត្រូវបានកាត់ទោសសម្រាប់អ្វីៗដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ទេ" ។

សេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តីឱ្យ ខៀវ សំផន បញ្ចប់នៅថ្ងៃនេះ ៕ **ស៊ុយឈាង**


# គ្រាន់តែត្រាំវានឹងទឹកធម្មតាសោះ មានប្រសិទ្ធភាពដល់ថ្លើមផង



ខ្មែរយើងតែងមានជំនឿលើឱសថបុរាណដែលជាវិធីសាស្ត្រធម្មជាតិព្យាបាលជម្ងឺស្ទើរគ្រប់ប្រភេទការព្យាបាលរបស់វា គឺមានអនុភាពខុសគ្នាទៅតាមប្រភេទនៃគ្រឿងផ្សំរបស់ថ្នាំ ។ ហើយខាងក្រោមនេះដែលគឺជាឱសថមួយប្រភេទដែលមានប្រសិទ្ធភាពជាច្រើនក្នុងការជំនួយដល់សុខភាពរាងកាយរបស់អ្នកឱ្យបានសុខភាពល្អរឹងមាំមិនងាយឈឺ ថែមទាំងអាចព្យាបាលនូវជម្ងឺមួយចំនួនឱ្យប្រែមកជាសភាពដើមវិញ ។

ចំពោះវិធីសាស្ត្រដែលយើងនឹងបង្ហាញនៅខាងក្រោមនេះ គឺអាចជួយអ្នកក្នុងការត្រួតពិនិត្យនូវសម្ពាធជាតិស្ករកាត់បន្ថយកូឡេស្តេរ៉ុលក្នុងសរសៃឈាមធ្វើឱ្យសំណើរឈាមរត់មានសុខភាពល្អពង្រឹងដល់ប្រព័ន្ធរាងកាយ ។

**គ្រឿងផ្សំ:**
ពោតបារាំង ៥ទៅ៧ផ្លែ
ទឹកធម្មតា ១ចាន

**ការរៀបចំ :**
**១.**សូមពុះផ្លែពោតបារាំងជា២ឬជា៤ ចម្រៀក ដាក់ចូលទៅក្នុងកូនចានមួយ ។
**២.**ចាក់ទឹកមួយកូនចានចូលរួចគ្របវាទុក និងត្រាំរយៈពេល១យប់ ។
**៣.**នៅពេលព្រឹកឡើងសូមស្រង់ផ្លែពោតបារាំងចេញ ។
**៤.**អ្នកត្រូវត្រងទឹកមួយនេះឱ្យបានស្អាតល្អការពារការនៅសល់គ្រាប់របស់ពោតបារាំង ។

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគំរាមសាជាថ្មីអំពីសង្គ្រាម ដើម្បីរក្សាអំណាចតទៅមុខទៀត

**ដោយ វណ្ណ រឿន | ថ្ងៃព្រហស្បតិ៍ ទី២២ ខែមិថុនា ឆ្នាំ២០១៧**

កាលពីម្សិលមិញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានងាកមកនិយាយរឿងសង្គ្រាមឡើងវិញ ដោយគំរាមសាជាថ្មីកម្ចាត់មនុស្សប៉ុន្មានរយនាក់ចោលដើម្បីបានគ្រប់គ្រងអំណាចទៅមុខទៀត និងបានចោទប្រកាន់គណបក្សប្រឆាំងថា បង្កសង្គ្រាមតាមរយៈពាក្យសំដីរបស់ខ្លួន ដោយមើលទៅហាក់បីដូចជាយុទ្ធនាការឃោសនាសម្រាប់ការបោះឆ្នោតឃុំសង្កាត់កាលពីថ្ងៃទី៤ខែមិថុនា មិនទាន់ចប់អ៊ីចឹង។

ស្ថិតក្នុងឯកសណ្ឋានយោធាលោកនាយករដ្ឋមន្ត្រីបានធ្វើដំណើរពីភ្នំពេញទៅខេត្តត្បូងឃ្មុំតាមឧទ្ធម្ភាគចក្រនាពេលព្រឹកព្រលឹមទៅកាន់កន្លែងដែលកាលពី៤០ឆ្នាំមុន លោកជាមេបញ្ជាការរងប្រចាំភូមិភាគដ៏វ័យក្មេងរបស់ខ្មែរក្រហម និងកន្លែងដែលលោកបានចុះចូលជាមួយវៀតណាម ហើយបានជួយបង្កើតកងកម្លាំងបះបោរដែលជួយផ្តួលរំលំរបបនេះ នៅឆ្នាំបន្ទាប់។

អង្គុយនៅទីវាលក្រោមកម្តៅថ្ងៃលើកៅអីឈើដែលមានបង្អែកក្នុងស្រុកកោះថ្ម អមដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឧត្តមសេនីយ៍កំពូលៗ លោក ហ៊ុន សែន ដែលនិយាយសំដៅចំៗដល់ការអំពាវនាវរបស់គណបក្សសង្គ្រោះជាតិឱ្យមានការផ្លាស់ប្តូរផ្នែកនយោបាយនោះ បានមានប្រសាសន៍ថា ពាក្យសម្តីអាចធ្វើឱ្យប្រទេសធ្លាក់ចូលក្នុងសង្គ្រាមដោយងាយ។

លោកបានមានប្រសាសន៍ថា "មិនចាំតែមានកាំភ្លើងទេ អណ្តាតអ្នកឯងក៏បង្កើតសង្គ្រាមដែរ"។ លោកបានបន្តថា "ដរាបណាអណ្តាតអ្នកឯង ការសរសេររបស់អ្នកឯងនៅតែប្រមាថមាក់ងាយ ខ្ញុំនៅតែនិយាយថា កម្ពុជានៅសល់សង្គ្រាមនៅឡើយ។ កុំធ្វេសប្រហែសឱ្យសោះ។ កងទ័ពត្រូវត្រៀមបម្រុងជានិច្ចដើម្បីបង្ក្រាបរាល់ចលនានៃការផ្តួលរំលំ និងការធ្វើឱ្យខូចខាតប្រទេសជាតិ"។

លោកនាយករដ្ឋមន្ត្រីបានលើកឡើងម្តងទៀតអំពីយុទ្ធនាការប្តេជ្ញាបង្ហូរឈាមដើម្បីរក្សាសន្តិភាពក្នុងតម្លៃណាក៏ដោយ ដោយទំនងជាផ្តោតគោលដៅចំៗលើលោក សម រង្ស៊ី ដែលត្រូវបានដាក់សម្ពាធឱ្យលាឈប់ពីតំណែងជាប្រធានគណបក្សសង្គ្រោះជាតិកាលពីដើមឆ្នាំនេះ ដោយសារច្បាប់ស្តីពីគណបក្សនយោបាយដែលត្រូវបានធ្វើវិសោធនកម្ម។អតីតប្រធានគណបក្សប្រឆាំងរូបនេះក៏បានបង្ខំចិត្តនិរទេសខ្លួនឯងទៅរស់នៅក្រៅប្រទេសផងដែរដើម្បីគេចពីការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារដែលមជ្ឈដ្ឋានទូទៅមើលឃើញថា មានជាប់ពាក់ព័ន្ធនឹងរឿងនយោបាយនោះ។

លោក ហ៊ុន សែន បានថ្លែងថា "អណ្តាតរបស់ពួកអ្នកជាមូលហេតុនៃសង្គ្រាមហើយបើសិនអស់លោកនៅតែនិយាយអំពីការប្រមាថការគំរាមសម្លាប់អស់លោកត្រូវត្រៀមក្តារមឈូសទុកឱ្យហើយ"។ លោកបានថ្លែងបន្តថា "ដើម្បីការពារប្រជាពលរដ្ឋរាប់លាននាក់ បើចាំបាច់ត្រូវកម្ចាត់១០០ ឬ២០០នាក់ក៏ត្រូវតែកម្ចាត់ដែរ។ អ៊ីចឹងសូមអ្នកស្តាប់ឱ្យច្បាស់... អ្នកណាក៏ដោយឱ្យតែមានគោលដៅបំផ្លាញសន្តិសភាពនេះ អ្នកនឹងទទួលផលនូវអ្វីដែលអ្នកចង់"។





លោក ហ៊ុន សែន បានមានប្រសាសន៍ថា "ត្រកូលហ៊ុន គឺត្រកូលរួមសុខរួមទុក្ខជាមួយប្រជាជនកម្ពុជា"។ លោកបន្ថែមថា "ត្រកូលហ៊ុន មិនមែនយកប្រទេសនេះជាប្រទេសផ្តាច់មុខតែខ្លួនឯងទេ។ ត្រកូលហ៊ុនធានាការពារនូវសន្តិភាពសម្រាប់ប្រទេសនេះ។ សុំអ្នកទាំងឡាយកុំញុះញង់បង្កើតចលាចល"។

អំឡុងពេលធ្វើយុទ្ធនការឃោសនាបោះឆ្នោតគណបក្សសង្គ្រោះជាតិបានច្រានចោលការអះអាងដែលថា **តទៅទំព័រទី ១៥**

# 'PREPARE YOUR COFFIN': HUN SEN REPEATS BLOODY POWER PROMISE

With sons in tow, the prime minister warns against threats to his family

**by Van Roeun | June 22, 2017**

As if the June 4 commune elections race had never ended, Prime Minister Hun Sen returned to his bellicose campaign talk on Wednesday by once again threatening to kill hundreds to stay in power and accusing the opposition of fomenting war with its words.

Dressed in his formal military greens, the prime minister left Phnom Penh for TbongKhmum province by helicopter in the early morning to visit the place where, 40 years ago as a young deputy regional commander for the Khmer Rouge, he defected to Vietnam and helped found a rebel force that would aid in toppling the regime in 1979.

Seated outdoors in the sun behind a broad wooden desk in Koh Thma village, backed by his interior minister and top generals, Mr. Hun Sen-in a thinly veiled reference to the opposition CNRP's calls for political change-said words could easily plunge the country back into war.

"It is not a weapon, but your tongue is creating war," he said. "As long as your tongue and your writing insult me, I say that Cambodia is still at war. Do not be reckless. The army is ready to crack down on any movement to overthrow and undermine the country."

The prime minister repeated his bloody campaign promise to preserve peace at all costs, appearing to take direct aim at opposition figure Sam Rainsy, who was pressured to step down as CNRP president earlier this year by an amended political party law and lives abroad avoiding prison sentences for convictions widely seen as politically motivated.

"Your tongue is the reason for war. If you still make insults and threats to kill, you have to prepare your coffin," he said. "To protect the peace for millions of people, if necessary, 100 or 200 must be eliminated. Please listen carefully…. Whoever intends to undermine peace will receive what you deserve."

During the election campaign, the CNRP dismissed the government's claims that it had any violent intentions, insisting it had no weapons to start or fight a war. Kem Sokha, who succeeded Mr. Rainsy as CNRP president, sought to assure those in power that they would not be persecuted if replaced.

Election observers have praised the government for managing an Election Day largely unmarred by violence, but said the repeated warnings of war and violence from the prime minister and other top officials during the campaign helped prevent the election from being free and fair.

On Wednesday, however, Mr. Hun Sen admitted the power struggle was personal.

"There is an attempt to destroy the Hun family. The Hun family is not the family for you to attack for fun," he said, asking his three sons to stand behind him.

Lieutenant General Hun Manet, the oldest, heads the Defense Ministry's counterterrorism department and is deputy commander of his father's personal bodyguard unit. Major General Hun Manith, the prime minister's second son, is deputy commander of the military's powerful intelligence unit. Both came wearing their own military uniforms. Hun Many, the prime minister's youngest, is a National Assembly lawmaker for his father's ruling CPP.

"The Hun family is the family that shares your sorrows and the happiness of the Cambodian people," Mr. Hun Sen said. "The Hun family does not own a monopoly on this country. The Hun family ensures the protection of the country's peace. Please don't incite to foment turmoil." **Continued to Page 15**

"ទស្សនៈនយោបាយកម្ពុជា"

# ការគម្រាមរបស់ ហ៊ុន សែន ធ្វើឱ្យគេនឹកទៅដល់របបប៉ុលពត

**ដោយ ពិន សំខុន**

ខៀវ សំផន នឹង នួន ជា កំពុងការពារជីវិតនឹងកិត្តិយសខ្លួននៅតុលាការអន្តរជាតិយ៉ាងអស់សង្ឃឹម, តើពួកគាត់បានធ្វើអ្វីខុសកាលពិអតីតកាលឬ? មនុស្សមិនតិចជាង២លាននាក់ទេ ដែលបានត្រូវរងទារុណកម្មរហូតដល់ស្លាប់ក្នុងរណ្ដៅរួម កាលពីចន្លោះឆ្នាំ១៩៧៥-៧៩ ពេលដែល "ជនពាលទាំង៣"រាប់ទាំងប៉ុលពតផង នៅកាន់អំណាច។ ស្រាប់តែសប្ដាហ៏នេះទៀត គេឮលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ប្រកាសថា នឹងសម្លាប់មនុស្ស១០០-២០០នាក់ចោលទៀត បន្ថែមលើការសម្លាប់បើកមុខឬបិទមុខរាប់រយនាក់រួចហើយក្នុងរបបថ្មីរបស់គាត់ បើមានការដណ្ដើមអំណាចពីដៃរបស់គាត់ធ្វើនេះឱ្យគេនឹកឃើញថា ហេតុអ្វីក៏ទង្វើបច្ចុប្បន្ននៃអ្នកដឹកនាំពេលនេះ បែរជាធ្វើឱ្យយើងនឹកទៅដល់ឧក្រិដ្ឋកម្មនាអតីតកាលរបស់របប"ក្រុមប៉ុលពត"?

ក្រុមអាវខ្មៅបង់កក្រម៉ាបានធ្វើឱ្យប្រជាពលរដ្ឋខ្មែរញាប់ញ័ររន្ធត់ រហូតដល់បានធ្វើឱ្យគេសប្បាយសុខចិត្តឱនក្បាលឱ្យគេ"វាយនឹងដងចបដើម្បីបញ្ចប់ទុក្ខ", តើនេះវាខុសអ្វីនឹង "ក្រុមពាក់ផ្កាយឯកសណ្ឋានយោធាពណ៌ស្រអាប់" ដែលវាយដំបាញ់សម្លាប់នឹងយកទ្រព្យសម្បត្តិពីមនុស្សទន់ខ្សោយក្រខ្សត់គ្មានអាវុធយ៉ាងគ្មានត្រាប្រណី រហូតដល់គេរីករាយនឹងហុចដៃឱ្យដាក់ខ្នោះឱ្យគេបញ្ជូលគុកបញ្ចប់កង្វល់ដូចតែគ្នា។ ក្រុមទាំងពីរនេះ សុទ្ធតែបានសន្យាថា: "មកការពារពលរដ្ឋខ្មែរមករកសេចក្ដីចំរើនជូនប្រជាពលរដ្ឋខ្មែរ" តែចុងបញ្ចប់សម្លាប់ខ្មែរបង្ករការភ័យខ្លាចក្រោមផ្ទៃមេឃខ្មែរយ៉ាងគ្មានខ្មាសអៀននឹងការភូតភរកុហកជាក់ស្ដែងរបស់ខ្លួនដូចគ្នាអ្វីខុសពីគ្នាទេ។





"ក្រុមពាលអាវខ្មៅបង់កក្រម៉ា"មួយបានយក"របបកុម្មុយនីស្ត"ឈ្មោះកម្ពុជាប្រជាធិបតេយ្យមកធ្វើជាព្រះរបស់ខ្លួន ហើយបានធ្វើបដិវត្តន៏សម្លាប់ប្រជាពលរដ្ឋជាង២លាននាក់ដើម្បីបូជាព្រះរបស់គេតាំងពីឆ្នាំ១៩៧៥, រីឯ "ក្រុមពាលពាក់ផ្កាយមានឯកសណ្ឋានយោធា"មួយទៀតបានគ្រប់គ្រងបន្តនាឆ្នាំ១៩៧៩ ដោយរបប "កុម្មុយនីស្ត" ឈ្មោះកម្ពុជាប្រជាមានិតនៅបន្តបដិវត្តន៏សម្លាប់ពលរដ្ឋឯងប្រមាណ១លានហើយរហូតមកដល់សព្វថ្ងៃនេះ ក៏នៅតែគម្រាមសម្លាប់មនុស្សស្លូតត្រង់ឥតអាវុធមិនទាន់ឈប់នៅឡើយទេ។ គ្មានសម្ព័ន្ធមិត្តប្រជាពលរដ្ឋកម្ពុជាណាម្នាក់នៅឡើយ ដែលហ៊ានឈរពាំង ការពារពលរដ្ឋពីមុខអាវុធអ្នកដឹកនាំ"កុម្មុយនីស្ត"ខ្មែរនៅឡើយទេ ក្រៅតែពីសន្និសិទក្រុងប៉ារីសឆ្នាំ១៩៩១ ដែលបានបើកវង្វង់ក្រចកមកទប់ការបង្ហូរឈាមខ្មែរបាន៣-៤ឆ្នាំដែរ មុននឹងគេចេញទៅវិញ ទុកឱ្យខ្មែរស៊ីសាច់ហុតឈាមគ្នាបន្តទៅទៀត។

ក៏ប៉ុន្តែស្ថានភាពនយោបាយបានប្តូរផ្លាស់

**តទៅទំព័រទី ២០**



តមកពីទំព័រទី ១៣

# លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគំរាម...

ខ្លួនមានបំណងប្រើអំពើហិង្សាដោយលើកឡើងថា ខ្លួនគ្មានអាវុធដើម្បីចាប់ផ្តើម ឬធ្វើសង្គ្រាមទេ។ លោក កឹមសុខា ដែលឡើងជំនួសតំណែងលោក សម រង្ស៊ី ជាប្រធានគណបក្សសង្គ្រោះជាតិបានស្ទះស្ទែងធានាចំពោះអ្នកដែលកំពុងស្ថិតក្នុងអំណាចថា ពួកគេនឹងមិនត្រូវបានផ្តន្ទាទោសនោះឡើយ ប្រសិនបើមានការផ្លាស់ប្តូររដ្ឋាភិបាល។

ក្រុមអ្នកសង្កេតការណ៍បោះឆ្នោតបានលើកសរសើររដ្ឋាភិបាលសម្រាប់ការគ្រប់គ្រងមិនឱ្យមានអំពើហិង្សានៅថ្ងៃបោះឆ្នោត ប៉ុន្តែថា ការណែស (Global Witness) បានចេញរបាយការណ៍មួយដោយបង្ហាញអំពីអាណាចក្រជំនួញរបស់ត្រកូលហ៊ុន។ ដោយសារមានការសិក្សាស្រាវជ្រាវពីកំណត់ត្រាចុះបញ្ជីពាណិជ្ជកម្មតាមអ៊ិនធឺណិតរបស់រដ្ឋាភិបាលកម្ពុជាអង្គការមិនមែនរដ្ឋាភិបាលមានមូលដ្ឋាននៅចក្រភពអង់គ្លេសមួយនេះបានរកឃើញថា កូនៗរបស់លោកនាយករដ្ឋមន្ត្រី និងគ្រួសារដ៏ធំរបស់លោកមានភាគហ៊ុនមួយភាគធំនៅក្នុងក្រុមហ៊ុនជាង១០០ដែលមានទុនរួមសរុបជាង២០០លានដុល្លារនៅក្នុងវិស័យនានាគ្របដណ្តប់លើសេដ្ឋកិច្ច។ របាយការណ៍នេះព្រមានព្រមានច្រំដែលៗអំពីសង្គ្រាម និងអំពើហិង្សារបស់លោកនាយករដ្ឋមន្ត្រី និងមន្ត្រីកំពូលៗផ្សេងៗទៀតអំឡុងពេលធ្វើយុទ្ធនាការឃោសនានោះបានធ្វើឱ្យការបោះឆ្នោតនេះមិនសេរី និងយុត្តិធម៌។



ទោះជាយ៉ាងណា កាលពីម្សិលមិញ លោកហ៊ុន សែន បានទទួលស្គាល់ថា ការតស៊ូ ដើម្បីអំណាច គឺជារឿងគ្រួសារ។ ដោយសួរកូនៗបីនាក់របស់លោកដែលឈរពីក្រោយលោកបានមានប្រសាសន៍ថា "មានការប៉ុនប៉ងកម្ទេចត្រកូលហ៊ុន។ ត្រកូលហ៊ុន មិនមែនជាត្រកូលសម្រាប់ឱ្យអ្នកឯងវាយលេងទេ"។

លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត ដែលជាកូនច្បង គឺជាប្រធាននាយកដ្ឋានប្រឆាំងភេរវកម្មនៃក្រសួងមហាផ្ទៃ និងជាមេបញ្ជាការរងនៃកងអង្គរក្សផ្ទាល់របស់ឪពុកលោក។ លោកឧត្តមសេនីយ៍ទោ ហ៊ុន ម៉ានិត កូនប្រុសទី២របស់លោក ហ៊ុន សែន គឺជាមេបញ្ជាការរងនៃអង្គភាពចារកិច្ចដ៏មានឥទ្ធិពលនៅក្រសួងនេះ។ កូនប្រុសទាំងពីររូបនេះសុទ្ធតែស្ថិតក្នុងឯកស្ថានយោធាពេលអមដំណើរឪពុករបស់លោក។ លោកហ៊ុន ម៉ានី កូនប្រុសពៅរបស់លោកនាយករដ្ឋមន្ត្រីគឺជាសមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចរបស់ឪពុករបស់លោក។

កាលពីខែកក្កដា ឆ្នាំមុន អង្គការគ្លូបលវីតវិនិយោគិនបរទេសទាំងបច្ចុប្បន្ន និងនាពេលអនាគតអំពីហានិភ័យក្នុងការរកស៊ីជាមួយក្រុមហ៊ុនទាំងនេះដែលក្នុងនោះមានមួយចំនួនត្រូវបានរកឃើញថា រំលោភលើច្បាប់ដោយមិនជាប់ទោសពៃរ៍ ក្នុងបរិយាកាសប្រកបដោយអំពើពុករលួយក្រោមការគ្រប់គ្រងរបស់លោកហ៊ុន សែន។

នៅពេលនោះកូនៗរបស់លោកនាយករដ្ឋមន្ត្រី បានរិះគន់ខ្លាំងៗលើរបាយការណ៍នេះ និងស្ថាប័នព័ត៌មានក្នុងស្រុកចុះផ្សាយជាភាសាអង់គ្លេសដែលបានចុះផ្សាយអត្ថបទពាក់ព័ន្ធនឹងរបាយការណ៍នេះ។ កូនៗរបស់លោក ហ៊ុន សែន អះអាងថា របាយការណ៍នេះមានភាពមិនត្រឹមត្រូវច្រើន ប៉ុន្តែមិនបានគូសបញ្ជាក់ថា ខុសត្រង់ណាខ្លះនោះទេ លើកលែងតែឋានន្តរស័ក្តិយោធារបស់ឧត្តមសេនីយ៍ទោ ហ៊ុន ម៉ានិត ដែលថាសរសេរខុសនៅក្នុងរបាយការណ៍។

កាលពីម្សិលមិញ លោកនាយករដ្ឋមន្ត្រីក៏បានចែកអំណោយយ៉ាងច្រើនដល់អ្នកភូមិនៅក្នុងតំបន់ដែលលោកបានចុះទៅផងដែរ ហើយបន្ទាប់មកលោកបានដើរតាមផ្លូវដែលលោកធ្លាប់ប្រើដើម្បីភៀសខ្លួនកាលពី៤០ឆ្នាំមុនទៅកាន់ប្រទេសវៀតណាម។ លោកត្រូវបានមន្ត្រីវៀតណាមទទួលស្វាគមន៍យ៉ាងកក់ក្តៅនៅព្រំដែនដោយមានទាំងការជូនផ្កាផងដែរកាលពីម្សិលមិញ។ **ស៊ុយឈាង**

Continued from page 13

## 'PREPARE YOUR COFFIN': HUN SEN...

In July last year, Global Witness released a report exposing the Hun family's sprawling business empire. By combing through the Cambodian government's online business registry records-since scrubbed of shareholder information-the U.K. NGO found that the prime minister's children and extended family had significant shares in more than 100 companies with a combined capital of more than $200 million in sectors spanning the economy.

It warned current and prospective foreign investors of the risks of doing business with the companies-some of them accused of abusing the law with impunity-in a highly corrupt environment under Mr. Hun Sen's virtually unchecked control.

At the time, the prime minister's children bashed the report and the local English-language media that published articles about it. They claimed it was full of inaccuracies but pointed out none, save Maj. Gen. Manith's military rank.

At on Wednesday ceremony, the prime minister donated piles of food to area villagers, then leisurely retraced his escape 40 years ago to Vietnam, where he was greeted at the border by Vietnamese officials with a large bouquet of flowers.





**ការវិភាគ**

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

**ព្រះសង្ឃមួយអង្គលេងកាំភ្លើងជ័រត្រូវអាជ្ញាធរខ្មែរ**
**និងតុលាការចាប់ផ្សឹកដាក់ព័ន្ធនាគារ**

សមាជិកបណ្តាញព្រះសង្ឃមួយព្រះអង្គ ព្រះនាម **ហាន សុផាន្នី** ព្រះជន្ម២៤ព្រះវស្សា គង់នៅវត្តដំរីស ក្រុងបាត់ដំបង ត្រូវបានសមត្ថកិច្ច កាន់ដីកាពីតុលាការបង្គាប់ឲ្យនាំខ្លួនព្រះអង្គ ហើយសហការជាមួយមន្ត្រីសង្ឃចាប់ផ្សឹកព្រះអង្គដោយបង្ខំ រួចបញ្ជូនទៅឃុំនៅព័ន្ធនាគារ ដោយបទចោទថា ទុកកាំភ្លើងខុសច្បាប់និងញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ តាមដំណឹងថា ករណីនេះ មានហេតុកើតឡើងតាំងពីខែមីនា២០១៧ ដែលព្រះភិក្ខុ ហន សុផាន្នី បានសុំកាំភ្លើងជ័រពីក្មេងហើយធ្វើជាពោបបាញ់ ហើយគេឃើញក្នុងហ្វេសប៊ុកមានអក្សរដាក់ថា ត្រូវរក្សាសន្តិសុខ។ ការថតបង្ហោះតាមបណ្តាញសង្គមនេះ ទំនងជាអង្គដទៃថតផ្សាយ។ បញ្ហានេះ ត្រូវបានសម្រួលគ្នាអស់ហើយ ដោយព្រះភិក្ខុហន សុផាន្នី បានសន្យាថា ឈប់លេងល្បែងនេះទៀតហើយ រឿងនេះកន្លងទៅប្រហែល២ខែហើយ ស្រាប់តែនៅថ្ងៃ២២មិថុនានេះ បែរទៅចាប់លោកផ្សឹកដាក់ព័ន្ធនាគារ។ រឿងនេះ អ្នកសង្កេតការណ៍សង្ស័យថាជារឿងទាក់ទងនយោបាយ ព្រោះក្រុមសមាជិកបណ្តាញព្រះសង្ឃទាំងនោះធ្វើការសកម្មណាស់ក្នុងបញ្ហាសង្គម ជាពិសេស អំឡុងពេលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ព្រះភិក្ខុហនសុផាន្នីបានទៅយកពត៌មាននៅឃុំអូរចា ដែលកញ្ញាស៊ិនពៅវ៉ូហ្សែត ខាងគណបក្សសង្គ្រោះជាតិបានឈ្នះជាប់ជាមេឃុំ។

ឥឡូវនេះ ទាំងអស់គ្នាពិចារណាមើល កាន់លេងកាំភ្លើងជ័រ កាត់ឲ្យមានទោសថា ដឹកជញ្ជូនអាវុធកាន់កាប់ដោយខុសច្បាប់ និងញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ តើអាជ្ញាធរខ្មែរ និងតុលាការចង់និយាយថាម៉េច ? កាំភ្លើងក្មេងលេងថាកាន់កាប់អាវុធខុសច្បាប់ ហើយញុះញង់ឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋ តើអ្នកណាញុះញង់ឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋ ? បើកាំភ្លើងជ័រនេះខុសច្បាប់ហេតុអ្វីបានអនុញ្ញាតឲ្យកាំភ្លើងជ័រនេះចូលមកដល់ប្រទេសខ្មែរ ហើយហេតុអ្វីក៏មិនទៅចាប់អ្នកដែលលក់ ? មួយទៀត មិនបានស៊ើបអង្កេតឲ្យបានម៉ត់ចត់ផង មិនបានកោះហៅអ្នកជាប់ចោទទៅបំភ្លឺផង ស្រាប់តែឲ្យនាំខ្លួន ហើយចាប់ផ្សឹកតែម្តងហើយដាក់ពន្ធនាគារ នេះបញ្ជាក់ថា អាជ្ញាធរបានគ្រោងទុករួចហើយជាមួយតុលាការថាត្រូវតែធ្វើបែបនេះ តើពិតទេ?បើមិនដោះលែងភិក្ខុហនសុផាន្នីហើយបំបួសវិញក្នុងពេលឆាប់ៗនេះទេ?ត្រូវឲ្យតុលាការពលរដ្ឋកាត់សេចក្តីតាមរយៈការបោះឆ្នោតឆ្នាំ២០១៨នេះ ៕

វត្តខ្មែរកាណាដា,ថ្ងៃ២៣មិថុនា២០១៧;www.hoksavann.org;savannhok@yahoo.com

# រមណីយដ្ឋាន ភ្នំគូលែន មានតំបន់កម្សាន្តអ្វីខ្លះ ?





ដោយ : ច័ន្ទ រស្មី

**ខេត្តសៀមរាប :** ភ្នំគូលែនមានរមណីយដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រជាច្រើនដូចជាតំបន់ទឹកធ្លាក់ ព្រះអង្គធំ វាលស្តេចគម្លង់ វាលព្រះសព ព្រះក្រាល សំពៅធ្លាយ និងមានប្រាសាទតូចៗធ្វើអំពីឥដ្ឋជាច្រើនទៀត ដែលជាកេរដំណែលស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី២ កសាងឡើង ។ តំបន់ភ្នំគូលែនមិនត្រឹមតែជាតំបន់ទេសចរប៉ុណ្ណោះទេ គឺជាតំបន់កសិកម្មដីមានជីវជាតិអាចដាំដំណាំបានគ្រប់ប្រភេទដូចជា ចេក ខ្នុរ ដំឡូង ត្រាវ...ប្រកបដោយទិន្នផលខ្ពស់ ។

តំបន់ទឹកធ្លាក់ គឺជាប្រភពដើមកំណើតរបស់ស្ទឹងសៀមរាបហូរកាត់កណ្តាលទីរួមខេត្តចាក់ឆ្ពោះទៅកាន់បឹងទន្លេសាបមានទឹកថ្លាយង់ជាទីពេញនិយមរបស់ងូតលេងកម្សាន្ត ។ ទឹកជ្រោះធ្លាក់សំយុងទៅប៉ះនឹងថ្មដាបែកផ្កាត្រែងគួរឱ្យចង់ទស្សនា ។

នៅក្បែរទឹកជ្រោះធ្លាក់មានប្រាសាទ២ធ្វើអំពីថ្មបាយក្រៀមសង់អមសងខាងមាត់អូរដែលគេឱ្យឈ្មោះថា "ក្រាលរមាស" ប៉ុន្តែនៅប៉ែកខាងលិចត្រូវដួលរលំ និងបាត់ថ្មអស់មួយចំនួនធំនៅសល់តែខឿនជញ្ជាំងបន្តិចបន្តួចប៉ុណ្ណោះ ។





ចំណែកឯស្រះដំរីវិញមានបណ្តោយ១៥០ម៉ែត្រ និងទទឹង៧០ម៉ែត្រ ជម្រៅ៣ម៉ែត្រ ដែលមានរូបដំរី គោ ខ្លា ហើយរូបទាំងអស់នោះសុទ្ធសឹងតែរចនាចេញពីថ្មភ្នំទាំងអស់ ។

ស្តេចគម្លង់តាមចាស់ៗតំណាលថា ស្តេចតមថ្នាំព្រោះនៅទីនោះមាន ឆ្នាំងថ្នាំ និងវត្ថុតាងផ្សេងៗទៀតរាប់មិនអស់ ។ វាលនោះក្រាលថ្មទំហំធំ ហើយចំកណ្តាលមានអូរហូរកាត់អាង១សម្រាប់មនុស្សពីរទៅបីនាក់អង្គុយ និងអាង១ទៀតសម្រាប់មនុស្សម្នាក់ចុះងូតទឹក ។

វាលព្រះសពជាវាលក្រាលថ្មទំហំធំ ។ នៅលើវាលនោះមានព្រះវិហារ១តូចកសាងឡើងប្រហែលក្នុងសតវត្សទី១៩ ធ្វើអំពីឈើប្រក់ឈើ ។

ព្រះក្រាលទីនោះមានទំហំធំណាស់ ដែលមានពើងថ្មពីរ ពើងមួយមានទំហំ៦ម៉ែត្រគុណនឹង៥ម៉ែត្រ មានរូបចម្លាក់ដាប់ថ្មពើងនិយាយពីជីវភាពរស់នៅរបស់ប្រជាជននាសម័យនោះ រីឯពើងមួយទៀតមានដាប់ឆ្លាក់រូបមនុស្ស៥នាក់ត្រឹមពាក់កណ្តាលខ្លួនមកលើ ។

# ផ្លែទៀប មានអត្ថប្រយោជន៍ ចំពោះស្ត្រីមានផ្ទៃពោះ



អ្វីដែលអ្នកទទួលទានពេលមានផ្ទៃពោះបានប៉ះពាល់ដល់ការលូតលាស់ធំធាត់របស់ទារក។ ដូច្នេះអ្នកគួរប្រុងប្រយ័ត្នក្នុងការជ្រើសរើសអាហារសម្រាប់ខ្លួនឯង។ អ្នកជំនាញបានណែនាំពីប្រភេទផ្លែឈើដ៏អស្ចារ្យបំផុតមួយប្រភេទដល់ស្ត្រីមានផ្ទៃពោះគ្រប់រូបនោះ គឺផ្លែទៀប។ សាច់ទាបផ្ទុកទៅដោយវីតាមីនសារធាតុខនិជ ជាតិស្ករធម្មជាតិ ជាតិសរសៃ អាស៊ីតអាមីណូ និងជាតិខ្លាញ់ជំនួយសុខភាពជាច្រើន ដែលសុទ្ធតែជាតម្រូវការសារធាតុចិញ្ចឹមដល់រាងកាយស្ត្រី និងការលូតលាស់របស់គភ៌។

ខាងក្រោមនេះនឹងបង្ហាញពីអត្ថប្រយោជន៍នៃផ្លែទៀបចំពោះម្តាយ និងទារកៈ

ជួយដល់ការលូតលាស់ខួរក្បាល និងប្រព័ន្ធភាពស៊ាំរបស់គភ៌ផ្លែទៀបផ្ទុកទៅដោយសារធាតុចិញ្ចឹមចាំបាច់សំខាន់ៗ ជួយដល់ការលូតលាស់របស់គភ៌។ វាជាប្រភពនៃវីតាមីន C និងវីតាមីន B6 ជួយដល់ការផលិតកូឡាសែនបង្កើតជាលិកាតភ្ជាប់ ជួយដល់ការលូតលាស់ឆ្អឹង ឆ្អឹងខ្ចីសរសៃពួរសាច់ដុំ និងស្បែករបស់គភ៌។ តាមការស្រាវជ្រាវបានបង្ហាញថា ស្ត្រីមានគភ៌ខ្វះវីតាមីន C ធ្វើឱ្យខូចខួរក្បាលរបស់ទារក។

កាត់បន្ថយគ្រោះថ្នាក់នៃការរលូតកូនផ្លែទៀប ជាប្រភពនៃធាតុទង់ដែង។ ការសិក្សានិងពិសោធន៍កាលពីថ្មីៗនេះបានឱ្យដឹងថា កង្វះធាតុទង់ដែងងាយធ្វើឱ្យស្ត្រីរលូតកូន។ លើសពីនេះទៀត ធាតុទង់ដែងជួយដល់ការលូតលាស់សរសៃពួរសាច់ដុំ ស្បែក និងសរសៃឈាមរបស់គភ៌។

**បំបាត់អាការៈចាញ់កូន**

ការទទួលទានផ្លែទៀបអាចជួយការពារស្ត្រីមានផ្ទៃពោះពីអាការៈមិនស្រួលខ្លួនរៀងរាល់ព្រឹក។ វាជួយបំបាត់អាការៈចង់ក្អួត និងក្អួតចង្អោរ។

**ជួយរក្សាការឡើងទម្ងន់បានល្អ**

ផ្លែទៀប ជាប្រភពនៃជាតិស្ករធម្មជាតិជួយរក្សាការឡើងទម្ងន់របស់ស្ត្រីមានគភ៌។ ជាពិសេសស្ត្រីដែលទម្ងន់ស្រាលក្នុងកំឡុងពេលមានកូន។ ផ្លែទៀបជួយឱ្យស្ត្រីស្រេកឃ្លានអាហារ។

**បំបាត់អាការៈទល់លាមក**

ផ្លែទៀបផ្ទុកទៅដោយជាតិសរសៃ ជួយសម្រួលដល់ការបញ្ចេញចោល៕




**នាអំឡុងឆ្នាំ១៩៥០-៦០ តើមានអ្វីកើតឡើងនៅក្នុងជីវភាពគ្រួសារខ្មែរ!** ដោយ ខ្មែរផុសស.រ.អា

**តពីលេខមុន**

ចៅពិនយួរចានទទេស្រាក់មួយចៅថាចយួរចានស្រាក់ទទេមួយទៀតចេញដំណើរតាមលោកគ្រូនឹងលោក២អង្គទៀត ព្រះសង្ឃជើងវែង១និមន្តឥតមានទ្រនាប់ជើងទេតែនិមន្តលឿនធ្វើឱ្យកូនសិស្សលោកដើរផងរត់ផងស្ទើរតែមិនទាន់តែសំណាងល្អនៅតាមផ្លូវជាតិទៅខាងជើងមានផ្ទះប្រជាពលរដ្ឋមួយ១ដែរ ធ្វើឱ្យព្រះសង្ឃឈប់រង់ចាំ"ប្រោសសត្វ"គឺម្ចាស់ផ្ទះគេអាចដាក់បាយក្នុងបាត្រលោក ហើយកូនសិស្សត្រូវចូលឱ្យគេដាក់ចង្ហាន់ក្នុងស្រាក់ ។ និមន្តជិតដល់វត្តចំបក់មានផ្លូវមួយបែកពីផ្លូវជាតិខាងឆ្វេងដៃសំដៅចូលទៅចំបក់តាមផ្លូវដីដែលផ្លូវនោះមានតែអ្នកជិះកង់ជិះរទេះគោនឹងអ្នកដើរទេដែលប្រើផ្លូវនោះនិមន្តដល់ភូមិហើយផ្ទះអ្នកស្រុកក៏សម្បូរលោកគ្រូនាំមុខក្បួនបានឈប់ជាញឹកញយទទួលការដាក់បាត្រនឹងដាក់ចង្ហាន់ក្នុងស្រាក់ ហើយក៏ប្រទានពរសូត្រធម្មជយន្តោសេរីមង្គលជូនពុទ្ធបរិស័ទជាបន្តបន្ទាប់, តែដោយសារព្រឹកនេះមានកូនសិស្សលោកដល់ទៅ២នាក់ ហើយម្នាក់ជាកូនលោកកុម៉ង់ដង់បន្ទាយជើងខ្មៅ ធ្វើឱ្យលោកគ្រូមានមោទនភាពនឹងប្រាប់ញាតិញោមពីកុមារថ្មីម្នាក់នេះ ម្ល៉ោះហើយនៅពេលចូលទៅបំពេញម្ហូបក្នុងចានស្រាក់ មានខ្លះរីករាយណាស់នឹងដាក់នុំនែកក្នុងហោប៉ាវឱ្យ"អានាងកូនកុម៉ង់ដង់"ទុកហូបតាមផ្លូវ, ខ្លះក៏រំលឹកថា ធ្លាប់បានស្គាល់លោកកុម៉ង់ដង់ពីមុនមកដែរ, លោកកុម៉ង់ដង់មុាំង ជាទូទៅមានកេរឈ្មោះល្អក្នុងខេត្តកំពុងស្ពឺទាំងមូលទាំងកេរឈ្មោះខ្លួនលោកទាំងកងកម្លាំងរបស់លោកផងដែរ ។

នៅពេលម្ហូបពេញស្រាក់នឹងបាយពេញបាត្រលោកគ្រូក៏និមន្តត្រឡប់មកវត្តវិញ តែកូនសិស្សទាំង២ត្រូវឈប់សម្រាកតាមផ្លូវជារឿយ១ពីព្រោះស្រាក់ពេញដោយម្ហូបធ្វើឱ្យមានទម្ងន់ឥតឧបម្បមាកាន់តែយួរកាន់តែធ្ងន់ថ្ងៃកាន់ក្តៅដំណើរកូនសិស្សកាន់តែយឺត...លោកគ្រូនិមន្តកាន់តែដាច់ឆ្ងាយទៅហើយ លោកឥតបានងាកក្រោយមើលកូនសិស្សលោកកំពុងតែវេទនានៅឯក្រោយនោះទេ ។ លោកនិមន្តទៅដល់ក្លោងទ្វារចូលវត្តព្រឹត្តការមួយកើតឡើង គឺពូសាយនៅចាំទីនោះរួចជាស្រេចមុននឹងនិយាយអ្វីទាំងអស់ពូសាយសួរថា:

-"ព្រះតេជគុណ! ចៅពិនមាននៅជាមួយព្រះអង្គទេ?"ពីព្រោះពូសាយមិនឃើញចៅពិនដើរតាមក្រោយលោកគ្រូទេ លោកគ្រូងាកក្រោយក៏មិនឃើញដែរក៏មានសង្ឃដីការថា:

-"ចៅពិននឹងចៅថាចយួរចានស្រាកម្នាក់




វត្តខ្មែរសម័យបារាំងកាន់កាប់នៅសៀមរាប

មួយនៅពីក្រោយអាត្មាមុននេះបន្តិច... ទំនងជាបន្តិចទៀតមកដល់ហើយ..."ពូសាយទូលលោកគ្រូថា:

-"ព្រះតេជគុណនិមន្តទៅមុនទៅទុកឱ្យខ្ញុំកូណាទៅរកក្មេងទាំង២នាក់នោះ"។ ថាហើយក៏ស្ទុះទៅតាមទិសខាងជើង តាមផ្លូវដែលលោកគ្រូទើបតែនិមន្តមកឃើញស្រមោលមនុស្សព្រិច១ កំពុងដើរកណ្តាលថ្ងៃទំនងជាក្មេងទាំង២នាក់នោះហើយ...មែន! អ្នកទាំង២នោះមែនកំពុងតែដើរអូសជើងយឺត១ដៃកាន់ចានស្រាក់ម្នាក់មួយយ៉ាងណែនមិនឱ្យក្រពុប ឬក្រឡុកចេញបានឡើយ ។ ពូសាយទៅទទួលយកចានស្រាក់ពីដៃក្មេងទាំង២មកកាន់ខ្លួនឯង ហើយនាំគ្នាដើររហូតមកវត្តទាំងអស់គ្នាវិញ ក្រោមការរង់ចាំរបស់លោកគ្រូនឹងព្រះសង្ឃឯទៀត១យ៉ាងទន្ទឹង ។ ពូសាយដឹងថា ក្មេងអាយុ៥-៦ឆ្នាំ មិនអាចយួរចានស្រាក់មានម្ហូបពេញបានយូរទេ តែព្រះសង្ឃមិនបានយល់ដូច្នោះទេ នឹកថាក្មេងអាយុប៉ុណ្ណោះហើយមុខជាអាចធ្វើការនេះរហូតដល់ចប់បាន ។

លោកគ្រូប្តើមសួរថា:

-"លោកសាយប្រញាប់មកវត្តអីក៏ព្រឹកម្លេះ?" ពូសាយឆ្លើយថា

-"កូណា លោកគ្រូ! លោកកុម៉ង់ដង់ នឹងលោកស្រីមានការព្រួយបារម្ភថា យកចៅពិនទៅបិណ្ឌបាត្រជាមួយលោកគ្រូនៅឯចំបក់អាចនឹងនាំឱ្យមានការគ្រោះថ្នាក់ដោយម្តំនោះសម្បូរឥស្សរៈ បើគេដឹងថាចៅពិនជាកូនកុម៉ង់ដង់ ដែលតែងតែយកទាហ៊ានមកវាយពួកគេ! ហេតុនេះហើយបានជាតេជគុណខ្ញុំកូណាដេញខ្ញុំកូណាឱ្យមកតាមមើលបើមានបញ្ហាអ្វីឱ្យប្រញាប់ឱ្យដំណឹងទៅលោកភ្លាម!" លោកគ្រូសូម៉េតយល់ពីការព្រួយបារម្ភនេះ លោកជាអ្នកនៅជាមួយប្រជាពលរដ្ឋអាចដឹងពីចិត្តពលរដ្ឋទាំងនោះបានច្បាស់លាស់ហើយក៏ផ្តាំទៅវិញថា:

-"ប្រាប់ទៅញោមកុម៉ង់ដង់ ថាកុំឱ្យមានការបារម្ភអ្វី ពីព្រោះនៅចំបក់អាត្មាស្គាល់តែទាំងអស់ហ្នឹងជាប្រជាពលរដ្ឋដែលស្លូតត្រង់ស្គាល់បុណ្យស្គាល់បាប ហើយអាត្មាដឹងថា គេគោរពនឹងស្រឡាញ់លោកកុម៉ង់ដង់ណាស់ សូមមើលទៅចៅពិនព្រឹកនេះ អ្នកស្រុកអ្នកភូមិដាក់នុំនែកឱ្យពេញហោប៉ាវ ពីព្រោះតែគេស្រឡាញ់រាប់អានលោកកុម៉ង់ដង់នោះអី ប្រាប់ញោមកុម៉ង់ដង់ទៅថាកុំបារម្ភធ្វើអ្វី!" ពូសាយក៏តបលោកតាវិញថា

-"កូណាលោកគ្រូ! ខ្ញុំកូណាបានឃើញនឹងបានយល់ហើយ! ចាំខ្ញុំកូណាទៅរាយការជូនលោកកុម៉ង់ដង់នឹងលោកស្រីវិញ" ថាហើយក៏ថ្វាយបង្គំលាចេញទៅវិញ រីឯលោកគ្រូសូម៉េត ក៏ងាកមកអាចៅទាំង២ ហើយសួរថា:

-"ម៉េច ទៅរួចទេអាចៅ!" ទាំង២នាក់បែកញើសឱ្យរហាមតែតបស្មើគ្នាថា:

-"មិនអីទេលោកគ្រូ!" តែចៅពិនបន្ថែមថា:

-"ចានស្រាកនោះធ្ងន់បន្តិចពេលត្រឡប់មកវិញ លោកគ្រូ!" លោកគ្រូស្តាប់យល់ពីប្រយោគអ្នកទាំង២ ហើយក៏មានសង្ឃដីការបន្ថែមថា:

-"អើ! ចាំស្អែកឱ្យអាចៅធំ១ទៅជាមួយ ជួយកាន់ចានស្រាក់ពួកឯង ឮទេ?... ថាហើយលោកក៏និមន្តទៅបន្តកាងាររបស់លោកតទៅទៀតទៅ! តែមុននឹងចេញទៅលោកគ្រូបន្តថា...ទៅ! នាំគ្នាទៅងូតទឹក រួចសឹមមកហូបបាយ..."

ការបារម្ភរបស់លោកស្រីកុម៉ង់ដង់ពីរឿងឥស្សរៈអីនោះ គ្រាន់តែជាលេសគ្រប់គ្រាន់សម្រាប់ឱ្យប្តីចាប់អារម្មទៅរកកូនតែប៉ុណ្ណោះតាមពិតទៅនៅពេលដែលពូសាយប្រាប់ថា កូនលោកស្រីនឹងចេញទៅជាមួយលោកបិណ្ឌបាត្រនៅឯចំបក់នោះ គឺជាផ្លូវថ្មើជើងឆ្ងាយ ដែលចៅពិនមិនដែលដើរ ជាពិសេសចៅពិនទៅជាមួយលោកសង្ឃដែលមិនមានបទពិសោធន៍ពិការថែរទាំក្មេងនៅឡើយទេ ហើយចំណុចសំខាន់នោះគឺនៅចំបក់នេះហើយដែលលោកកុម៉ង់ដង់ត្រូវគ្រាប់បៀមជាប់ក្នុងខ្នងជើងតាំងតែពិមិនដល់១ឆ្នាំមុននេះសោះ។ អសន្តិសុខបានកើនឡើងបន្តិច នាឆ្នាំ១៩៥៣ ដោយសារបារាំងប្រកាសថាជិតដល់ពេលចេញពីកម្ពុជា ហើយប្រគល់អំណាចទាំងមូលឱ្យទៅរដ្ឋាភិបាលកម្ពុជា ជាប្រទេសឯករាជ្យដោយមិនឱ្យកើតមានសង្គ្រាមបាន។ ក៏ប៉ុន្តែនៅពេលនោះ ចលនាកុម្មុយនិស្តកំពុងមានប្រជាប្រិយភាពនៅជុំវិញពិភពលោក, ខាងកុម្មុយនិស្តវៀតណាម បានជួយឧបត្ថម្ភដល់គណបក្សប្រជាជននៅកម្ពុជាឱ្យចាប់កំណើតដើម្បីឱ្យអាចឈរឈ្មោះបោះឆ្នោតដណ្តើមអំណាចជាមួយគណបក្សឯទៀត១ តាមរយៈការបោះឆ្នោតសាកលមួយនៅឆ្នាំ១៩៥៦។ ហេតុនេះហើយបានជាអសន្តិសុខបានកើនកំដៅបន្តិចនាឆ្នាំ១៩៥៣នោះ ពីព្រោះក្រុមចលនានិមួយ១ចង់បង្ហាញខ្លួន ចង់បានឈ្មោះជាចលនារំដោះជាតិជាចលនាឥស្សរៈដូចជាទ្រង់ចន្ទរង្សី ក្រុមបះបោរ"សក្តិមួយធិញ"ក្រុមសក្តិបីសៀបជាដើម។

ស្អែកឡើង ពូសាយ នាំកូនកុម្មង់ដង់ មុាំងមកប្រគេនលោកគ្រូដូចម្សិលមិញដែរ ចៅពិនមានអារម្មណ៍រីករាយនឹងមកនៅវត្តណាស់ពីព្រោះមានគ្នាលេង ហើយកូនសិស្សលោកដល់ទៅ២នាក់ បំរើលោកគ្រូតែមួយអង្គមិនធ្ងន់ធ្ងរអ្វីទេ។ ពេលលោកគ្រូចេញទៅបិណ្ឌបាត្រព្រឹកនេះ មានកូនសិស្សលោកធំម្នាក់ទៅជាមួយដែរដូចដែលលោកគ្រូបានសន្យារ គឺជាអ្នកជួយសម្រាលការកាន់ចានស្រាក់សិស្សតូច១បានយ៉ាងច្រើន។ ព្រឹកនេះ លោកគ្រូមិននាំមុខទៅបិណ្ឌបាត្រនៅចំបក់ទៀតទេ ទុកឱ្យលោកផ្សេងទៀត និមន្តទៅទីនោះម្តង ព្រះអង្គនិមន្តដោយជើងទទេ តាមវិន័យនៃនិកាយធម្មយុត្តទៅម្តុំរកាធំវិញម្តងដែលតំបន់នោះនៅមិនឆ្ងាយពីវត្តថ្មីប៉ុន្មានទេនៅជុំវិញនោះសុទ្ធសឹងជាឧបាសិកា-ឧបាសកជើងវត្តទាំងអស់ **តទៅលេខក្រោយ**

# ថវិការប្រហែល ៣៦០ ពាន់ដុល្លារ ដើម្បីចងក្រងឯកសារពីប្រវត្តិជនភៀសខ្លួន និងជនអន្តោប្រវេសន៍ក្នុងក្រុងឡូវែល

**ប្រែសម្រួលដោយខ្មែរផុស ស.រ.អា**

**ឡូវែល-** កាលពីពេលថ្មីៗនេះ សាកលវិទ្យាល័យម៉ាសាជូសេតឡូវែល ហៅកាត់ UMASS Lowell បានទទួលជំនួយថវិការសរុបចំនួន ២៣៩,000ដុល្លារអាមេរិក ពីអង្គការ National Endowment for the Humanities និងថវិការចំនួន២៨,000ដុល្លារពីការិយាល័យ Creative Economy Fund របស់អគ្គនិយកសកលវិទ្យាល័យ UMASS Lowell សម្រាប់ដំណើរការគម្រោងរក្សាទុកឯកសារឌីជីថលអាស៊ីអាគ្នេយ៍ (Southeast Asian Digital Archive)។

ជាមួយនឹងថវិការនេះ បណ្ណាល័យសាកលវិទ្យាល័យម៉ាសាជូសេតឡូវែល និងមជ្ឈមណ្ឌលដើម្បីការសិក្សាអាស៊ាន-អាមេរិក នឹងធ្វើការបង្កើតបណ្ណុំរក្សាទុកឯកសារឌីជីថល ដើម្បីប្រមូល និងចងក្រងនូវរាល់ឯកសារនៃប្រវត្តិសាស្ត្រជនភៀសខ្លួន និងជនអន្តោប្រវេសន៍មកពីអាស៊ីអាគ្នេយ៍ ដែលរួមមាន កម្ពុជា, វៀតណាម, ឡាវ, ភូមា និងប៊ូតាន់ នៅក្នុងក្រុងឡូវែលចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៧0។ ការប្រមូលឌីជីថលនឹងក្លាយជាធនធានដ៏សំខាន់មួយសម្រាប់គ្រូបង្រៀន, សិស្ស, បញ្ញាវន្ត, និងសមាជិកក្នុងសហគមន៍ក្នុងការសិក្សាស្រាវជ្រាវ និងការចំណើងពីប្រវត្តិសាស្ត្រ។

គម្រោងរក្សាទុកឯកសារឌីជីថលអាស៊ីអាគ្នេយ៍នេះ នឹងមានរួមបញ្ចូលរូបភាពប្រហែល៦៣,000 បានមកពីកាសែត, ឯកសារផ្សេងៗ, សៀវភៅ និងប័ណ្ណផ្សព្វផ្សាយ ហើយនឹងមានខ្សែអាត់សម្លេង និងវីដេអូជាច្រើនដែលមានរយៈពេលប្រហែល ៦២0ម៉ោង ដែលភាគច្រើននៃខ្សែអាត់សម្លេង និងវីដេអូបានមកពីការជួយឧបត្ថម្ភពីសំណាក់ស្ថាប័ណ្ណចំនួន៨ មានដូចជា សមាគមន៍ខ្មែរ CMAA, ក្រុមរបាំអង្គរ និងអង្គភាពរៀបចំបុណ្យអុំទូកអាស៊ីអាគ្នេយ៍។




រូបភាពបណ្ណាល័យរបស់មហាវិទ្យាល័យ UMASS Lowell នៅ South Campus

ចំពោះគម្រោងនេះបណ្ណាល័យរបស់សាកលវិទ្យាល័យម៉ាសាជូសេតឡូវែល និងមជ្ឈមណ្ឌលដើម្បីការសិក្សាអាស៊ាន-អាមេរិកនឹងចាប់ដៃគូរជាមួយនឹងស្ថាប័ណ្ណចំនួន ៦ ដូចជា ក្រុមរបាំអង្គរ, សមាគមន៍ខ្មែរ CMAA, កាសែតខ្មែរផុសស.រ.អា, ឧទ្យានប្រវត្តិសាស្ត្រជាតិឡូវែល, មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍សាយដានា និងមជ្ឈមណ្ឌលប្រវត្តិសាស្ត្រឧស្សាហកម្មស្លូង ដើម្បីអនុវត្តន៍គម្រោងខាងលើនេះ។

ជាងនេះទៅទៀត គម្រោងនេះក៏នឹងរួមបញ្ចូលឯកសារជាច្រើនរបស់គម្រោងរក្សាទុកឯកសារដែលមានស្រាប់នៃមូលនិធិជនភៀសខ្លួនឥណ្ឌូចិន ដែលមានទីតាំងស្ថិតនៅមជ្ឈមណ្ឌលដើម្បីសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រឡូវែលនៃសកលវិទ្យាល័យ UMass Lowell ហើយដែលមូលនិធិនេះ បានជួយក្នុងការតាំងទីលំនៅឡើងវិញនៃការហូរចូលយ៉ាងច្រើននៃជនភៀសខ្លួនកម្ពុជា ដែលបានចាប់ផ្តើមចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧0។ **តទៅទំព័រទី ២១**

## បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៍ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័ត៌មានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial

45, Merrimack Street, #218A

Lowell, Lowell MA 01852_USA

សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

យើងជឿជាក់ថា គំនិត យោបល់ នឹងព័ត៌មានពីលោកអ្នកនឹងជួយជាប្រយោជន៍ដល់សហគមន៍ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង។ **-សូមអរគុណ-**


## កាសែតដែលបំរើសហគមន៍ខ្មែរមានអ្នកអានច្រើនជាងគេបង្អស់នៅឆ្នេរខាងកើតសហរដ្ឋអាមេរិកតាំង១០ឆ្នាំមកហើយ

**KhmerPost USA, LLC**

សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម **Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ **Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

ការីនិពន្ធ Staff Writers:

អ្នកនិពន្ធកិត្តិយស **Contributing Writers:**

Richard Howe Jr,

**ច្នៃសោភ័ណភាពកាសែត Design Artist**

Heng Chhunleng

**ជំនួយការរដ្ឋបាល** Office Coordnator

Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

(អស័យដ្ឋានអ្នកផ្ញើរ)

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២.....................................................................................................

**អត្ថបទក្នុងសំបុត្រនេះ:**
**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការ៉ខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ




# តមកពីទំព័រទី ១៤ ការគំរាមរបស់ ហ៊ុន សែន ធ្វើឱ្យគេនឹក...

កាលពីពេលបោះឆ្នោតឆ្នាំ២០១៣នឹងឆ្នាំ ២០១៧ នេះ, អ្នកនយោបាយស្នេហាជាតិ២ក្រុម បានចាប់ដៃគ្នាផ្តួបកម្លាំងជាចលនា"សង្គ្រោះជាតិ" បានចេញមុខទប់ទល់នឹងចរន្តកម្មុយនិស្តដែលគ្រប់គ្រងដោយអំណាចផ្តាច់ការនិយមលើកម្ពុជា, ជាមួយគ្នានោះប្រជាពលរដ្ឋបានក្រោកឡើងព្រមគ្នាជាមួយចលនាសង្គ្រោះជាតិនោះ បានធ្វើពេលនោះហើយដែលជនផ្តាច់ការមើលឃើញថា" ក្ការម្សួលដែលគម្រាមថាធ្វើទុកឱ្យសង្គ្រោះជាតិ នោះ តើមែនទែនទៅសម្រាប់នរណា? គឺសម្រាប់ខ្លួនឯងទៅវិញទេ!"។

ពលរដ្ឋខ្មែរមកដល់ដំណាក់ការ មាន "ភាពចាស់ទុំ"គ្រប់គ្រាន់ចេះពិចារណាបានហ្មត់ចត់ ដោយមិនចាំបាច់"សង្គ្រោះជាតិ"ទេ, ដូចគ្នានឹងគណបក្ស



ឱ្យ "ក្រុមជនពាលភ្នំពេញ"ព្រួយបារម្ភនឹងរក្សាអំណាចមិនបានជាខ្លាំង, ប្រជាពលរដ្ឋខ្មែរបានសច្ចាដោយកំពុងតែបង្ហាញថា"ត្រូវហ៊ានប្រថុយ ទើបមានការផ្លាស់ប្តូរអំណាច"ពីដៃជនផ្តាច់ការបាន។ យោងតាមស្ថានការនយោបាយបច្ចុប្បន្ន "អ្នកហ៊ាន" ប្រឈមមុខនឹងលោក ហ៊ុន សែន មុខតែបានជាប់គុក ឬក៏ស្លាប់ខ្លួន, ក៏ប៉ុន្តែ "អ្នកខ្លាច" វិញក៏មិនបានរួចខ្លួនដែរទេ បើមិនរងទុក្ខទារុណកម្ម ក៏មុខតែនឹងស្លាប់មុនអស់អាយុដែរ គ្រាន់ទេមុននឹងក្រោយតែប៉ុណ្ណោះ ហេតុនេះហើយបានជាគេសង្កេតឃើញប្រជាពលរដ្ឋខ្មែរ កាន់តែច្រើនឡើងហ៊ានចេញមុខប្រថុយជីវិតការពារសិទ្ធខ្លួន សេរីភាពរហូតដល់ការពារប្រជាជាតិដោយខ្លួនឯង ហើយមិនមែនតែ២-៣នាក់ទេ តែចំនួនដល់ទៅរាប់លាននាក់ទៅហើយ ។ "វិរនារី នឹង វិរបុរសជាតិខ្មែរ"នាពេលនេះ គេរាប់លែងអស់ហើយពាក្យគម្រាមរបស់មេបក្សប្រជាជនកម្ពុជាបានក្លាយទៅជាខ្យល់ បើទោះជាថា ពាក្យរបស់គាត់ជាពាក្យពិតក៏ដោយ ពីព្រោះ"វិរបុរស-វិរនារីជាតិ" ទាំងឡាយនោះ បាន "ប្រថុយ ឬបូជាជីវិត" ជូនការផ្លាស់ប្តូររបស់ប្រជាជាតិរួចទៅហើយ ហើយចំនួននេះកំពុងកើនឡើងរាល់ថ្ងៃ។ សម្លេងឆ្នោតថ្ងៃទី៤មិថុនាកន្លងទៅនេះ មានគម្លាតពីគ្នាតែ ៣%តែប៉ុណ្ណោះ នេះបញ្ជាក់ថា បើទោះជាលោកមេទ័ព ហ៊ុន សែន គម្រាមខ្លាំងខ្លាប៉ុណ្ណាក៏ដោយ កំណើននៃអ្នកបូជាជីវិតដើម្បីការពារជាតិបានផុសចេញមកហើយ នឹងកើនផុតកម្លាំងអ្នកជឿលើ "កងទ័ពពាក់ផ្កាយ"ដាច់ស្រឡះ នាឆ្នាំ២០១៨, សង្គ្រោះជាតិដែលមានចំណាស់អាចដំណើរការដោយគ្មានវត្តមានលោក សម រង្សី ជាប្រធានដែរ, មានន័យថា ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាគណបក្សសង្គ្រោះជាតិនឹងមិនស្លាប់ដោយសារតែគ្រាប់កាំភ្លើងលោក ហ៊ុន សែន នោះទេ ដោយសារតែកាលណាលោក ហ៊ុន សែន ស្រែកគម្រាមកាន់តែខ្លាំងពេលណាប្រជាពលរដ្ឋនឹងព្ទសម្លេងអ្នកបំរើផលប្រយោជន៍"យួន" ហើយនាំគ្នាផុសផុល ក្រោកឡើងការពារប្រទេសជាធ្លុងមួយកាន់តែមាំ រហូតដល់"ក្រុមជនពាល"នោះធ្លាក់ពីអំណាច។

នរណាមិនដឹងថា ការប្រើកាំភ្លើងគម្រាមសម្លាប់អ្នកស្នេហាជាតិជាអំពើដ៏កំសាកនឹងដ៏ល្ងង់ខ្លៅដូចគ្នានឹង ខៀវ សំផន - នួន ជាមេបក្ស "អាវខ្មៅបង់កក្រម៉ា"ដែលគ្រប់គ្រងអំណាចប្រទេសកម្ពុជាទាំងមូល ទើបនឹងសារភាពប្រាប់តុលាការអន្តរជាតិថា "ខ្លួនមិនបានដឹងថា មានការសម្លាប់រង្គាលក្នុងប្រទេសរបស់ខ្លួន ហើយយួននៅពីក្រោយខ្នងនៃការកាប់សម្លាប់ប្រជាពលរដ្ឋទាំងនោះ" នេះបានហៅថាល្ងង់មែន! ពួក "កុម្មុយនីស្ត" បានបង្ហាត់បង្ហាញអ្នកដឹកនាំឱ្យស្រឡាញ់អំណាចមានមោទនភាពជា"អ្នកស្នេហាជាតិផ្តាច់មុខដោយកម្លាំងគម្រាមឱ្យគេខ្លាច" ដូចជាកូនក្មេង! ប៉ុន្តែប្រជាពលរដ្ឋខ្មែរ កំពុងតែប្រដៅ "ពួកកូនក្មេង" ដែលចង់ដឹកនាំប្រទេសទាំងនោះ ពីរបៀបគ្រប់គ្រងប្រទេសឱ្យបានជឿនលឿននឹងយូរអង្វែង ដោយ "អំណាចចែករំលែក-សុច្ចរឹត-យុត្តិធមិ នឹងដោយក្តីស្រឡាញ់"នោះ គេនឹងធ្វើរបៀបណា! ៕

## តមកទំព័រទី ១៩ ថវិការប្រហែល៣៦០ពាន់លាន....

ក្រុងឡូវែល គឺជាក្រុងមួយដែលមានការផ្លាស់ប្តូរអស់រយៈពេលជាច្រើនទសវត្សរ៍ដោយជនភៀសខ្លួនមកពីប្រទេសកម្ពុជា និងជនអន្តោប្រវេសន៏មកពីអាមេរិកឡាទីន និងអាហ្វ្រិច។ បច្ចុប្បន្ននេះ ពលរដ្ឋអាស៊ីអាមេរិកមានចំនួនប្រហែលច្រើនជាង22% នៃចំនួនប្រជាជនសរុប ក្នុងក្រុងឡូវែលដោយក្នុងនោះសហគមន៏ខ្មែរ គឺធំជាងគេបំផុតទីពីរក្នុងចំណោមសហគមន៏ផ្សេងទៀតក្នុងសហរដ្ឋអាមេរិក។



ការងារចង់ក្រងឯកសារនេះ មជ្ឈមណ្ឌលសេវាឌីជីថលនៃសកលវិទ្យាល័យម៉ាសាជូសេតឡូវែល ដោយចាប់ផ្តើមតាំងពីឆ្នាំ២០១៦ បានប្រមូលផ្តុំព័តិមានរាល់ការចុះផ្សាយរបស់កាសែតខ្មែរផុសដែលមានចាប់តាំងពីលេខចេញផ្សាយដំបូងដោយថតចំឡងពីក្រដាស់កាសែតសម្រួលទៅជាឯកសារឌីជីថល PDF ហើយការប្រមូលនេះ នូវកំពុងដំណើរការបន្តនៅឡើយ។ សូមបញ្ជាក់ថា អស់រយៈពេល១០ ឆ្នាំមកហើយដែលកាសែតខ្មែរផុសស.រ.អា បានធ្វើការចុះផ្សាយបានចំនួន២២៥ លេខរួមមកហើយរហូតមកដល់បច្ចុប្បន្ននេះហើយជាសរុបក្នុងរយៈពេល១០ឆ្នាំនេះ កាសែតច្រើនជាង១លានច្បាប់ហើយដែលបានចែកចាយដល់សហគមន៏យើងមានដូចជានៅ Massachusetts (Lowell & Lynn /Revere) និង Rhode Island (Providence & Cranston) ៕

ស្ថាប័ណ្ណជាដៃគូរក្នុងគម្រោងរក្សាទុកឯកសារឌីជីថលអាស៊ីអាគ្នេយ៍

---

# ដំណឹងរកបុគ្គលិកចែកផ្សាយ

ខ្មែរផុសស.រ.អា.ត្រូវការរកបុគ្គលិកសម្រាប់ចែកផ្សាយកាសែតនៅក្នុងតំបន់មានឡូវែល - លីន រីវែរ - ក្រេងស្តុន រ៉ូដអាយឡិន ។ កាសែតចែក២ដងក្នុង១ខែ ។ បេក្ខជនត្រូវមានប័ណ្ណបើកបរ នឹងធ្លាប់ស្គាល់តំបន់ច្បាស់លាស់ ។

សូមទាក់ទងមកទីស្នាក់ការយើង នៅលេខ **978 - 677 7163**

ឬទាក់ទងមក **សូបិន 978-656 8141**

---

Job Title : CHIEF OF STRATEGIC PLANNING, MONITORING AND EVALUATION
Department : DEPARTMENT OF ADMINISTRATION
Division : Rhode Island Health Benefits Exchange
Opening Date/Time : ed. 06/07/17 12:00 AM Eastern Time
Closing Date/Time : ed. 06/07/17 12:00 AM Eastern Time
Salary : $58.11 - $65.82 Hourly
$105,760.00 - $119,790.00 Annually
Pay Grade : 843A
Job Type : Non-Union (99)
Location: Louis Pasteur Campus, Rhode Island
Scheduled Work Days; Hours of Work
Unclassified; Standard : Monday - Friday; 9:00am - 5:00pm
Work Week : Non-Standard
Job # : 2470-80701-11

GENERAL STATEMENT OF DUTIES: At HealthSource RI, to be responsible for providing strategic direction and oversight to project management of a large scale complex intra-agency and/or inter-agency project, to ensure alignment and benefit realization, including all stages of the project management life cycle including conceptualization and determination of business needs; directing the project team; vendor management; system design, configuration, and development, testing, and implementation; developing the work plan and schedule; allocating resources; change control management; ensuring overall project success; plan, monitor, control and deliver project to a close and to manage beyond; manage project risk, scope, time, cost and completion; to be responsible for project delivery. Coordinate and exchange data and information with information technology vendors, insurance carriers, federal regulators, other state agencies and stakeholders; and to do related work as required.

SUPERVISION RECEIVED: Works under the general direction of the Director, and specifically the Deputy Director, with wide latitude for the exercise of initiative and independent professional judgment; work is reviewed through consultations and written reports for conformance to established policies and provisions of state and federal laws and regulations.

SUPERVISION EXERCISED: Plans, organizes, coordinates, and reviews the work of assigned professional, technical and support personnel, both contract workers and state staff.

**Illustrative Examples of Work Performed:**

- At HSRI, to be responsible for the overall management of a large scale complex intra/inter-agency project. To optimize performance across the project, functionally and technically, including all stages of the life cycle, including conceptualization and determination of needs and requirements; directing the project team; vendor management; system design, configuration and development, testing, and implementation; development of the work plan/schedule; allocating resources; change control management to ensure overall project success.
- To plan, monitor, control and deliver the project to close and beyond. To manage risk by scope, time, cost and completion. To align priorities of different teams, such that deliverables support HSRI's goals. To be responsible for the delivery of the project. Position project reviews with internal clients and vendors and manage their deployment.
- To work with state agencies, departmental technology coordinators, information technology staff, and consultants to understand, define and implement the project. To identify required processes, define problems, conduct needs analysis, develop concepts around potential solutions; evaluate existing systems and determine whether new or improved information systems are required.
- To define and document project goals and objectives, scope, roles and responsibilities, effort, cost and schedule estimates, major milestones, and risk management plan. To make determinations of user needs within HSRI and plan, coordinate, direct and supervise the work of staff engaged in systems analysis, programming, technical/network efforts and data programming procedures. To oversee implementation of the project with regard to resources, time, budget and quality.
- To provide leadership to cross functional teams through the duration of the project, all phases of the project lifecycle, managing the change process, coordinating actions and resolving conflicts through and beyond completion. To facilitate communication with project teams, vendors, management, sponsors, and other stakeholders in order to discuss on-going project issues, to resolve problems and to manage expectations; to write/present periodic progress, project status and problems resolution reports regarding information technology for management review and to do related work as required.
- To be responsible for managing, organizing, coordinating, reviewing and directing a staff engaged in carrying out overall responsibility for all activities to assure conformity and compliance with federal/state regulations and guidelines as related to providing health care insurance under the Comprehensive Federal Regulations of the Affordable Care Act. To be responsible for the delivery of an effective and timely reporting system to facilitate management decisions affecting HSRI.
- To do related work as required.

**Required Qualifications for Appointment:**

KNOWLEDGES, SKILL, AND CAPACITIES: A thorough knowledge and demonstrated expertise in project management, risk assessment and risk mitigation; a thorough knowledge of methods used to design and development information systems; knowledge of principles and methods used to plan or manage implementation, update and integration of information systems; a thorough knowledge of budget and planning procedures related to project management; ability to manage and motivate the project team; ability to monitor and inspect cost, work, and contractor performance; ability to identify problems, determine accuracy and relevancy of information, and analyze risks, establish contingency plans; the ability to organize work, set priorities, and determine resource requirements; the ability to establish and achieve short and long terms goals and strategies; the ability to coordinate with other stakeholders to accomplish goals, monitor progress, and evaluate outcomes; ability to challenge established culture and take explicit steps to transform; build organizational capacity for change; prepare for and deal with resistance; and related capacities and abilities.

---

## Job Opportunities Page

Job Title : DIRECTOR OF FINANCE /ASSOCIATE ADMINISTRATOR
Department : DEPARTMENT OF ADMINISTRATION
Division : Rhode Island Health Benefits Exchange
Opening Date/Time : Wed. 06/07/17 12:00 AM Eastern Time
Closing Date/Time : Sat. 07/08/17 11:59 PM Eastern Time
Salary : $61.89 - $69.75 Hourly
$112,643.00 - $126,951.00 Annually
Pay Grade : 844A
Job Type : Non-Union (99)
Bargaining Union: Non-Union (99)
Location: Louis Pasteur Campus, Rhode Island
Scheduled Work Days; Hours of Work
Unclassified; Standard : Monday - Friday; 9:00am -5:00pm
Work Week : Non-Standard
Assignment(s)/Comments : POSITION REPOSTED - Previous Applicants Need Not Reapply
Job # : 2470-80701-18

GENERAL STATEMENT OF DUTIES: To oversee all phases of the financial administration of HealthSource RI, including budgetary, expenditure control, financial planning, contracts, grants, trust, banking, and program evaluation; to develop, implement, oversee and be responsible for a financial planning and reporting system; to lead multiple audit processes and financial reporting requirements; to coordinate premium assessment billing, payments, write-offs and refunds; to identify, analyze and develop cost sharing opportunities; to coordinate with various vendors and HSRI Operations and; to do related work as required.

SUPERVISION RECEIVED: Works under administrative direction of a superior with wide latitude for the exercise of independent judgement and initiative; work is reviewed through consultation and review of submitted reports for conformance to laws, rules, regulations and policies.

SUPERVISION EXERCISED: Plans, organizes, supervises and reviews the work of professional, technical, clerical staff assigned to assist.

**Illustrative Examples of Work Performed:**

- To oversee all phases of HSRI financial administration, including budgetary, expenditure control, financial planning, contract management and program evaluation.
- To be responsible for evaluation of existing programs and to develop plans for modification in view of changing needs and the availability of state and/or federal funds.
- To be responsible for the overall supervision of the preparation and review of the departmental budget for central accounting, expenditure control and budgetary reports.
- To be responsible for conducting cost analysis surveys of various departmental operations with recommendations for reducing costs.
- To make recommendations on planning and developing systems in accordance with standards for effective administrative and fiscal management, including fiscal and staffing requirements.
- To monitor budget variances, analyze cause(s) and implement necessary adjustments.
- To develop, implement, oversee and be responsible for financial reporting.
- To do related work as required.

**Required Qualifications for Appointment:**
**KNOWLEDGES, SKILLS AND CAPACITIES:**

A thorough knowledge of governmental accounting principles, procedures and practices; a thorough knowledge of the principles, practices and procedures of program development and fiscal management; the ability to incorporate practices of business administration and fiscal management in developing complex programs for funding and budgeting; the ability to evaluate existing programs and to develop plans for their expansion, modification, or elimination; a thorough knowledge of the principles, practices and techniques involved in operating a financial reporting system; the ability to prepare and submit reports, studies and analyses relating to such services; the ability to establish effective working relationships with other governmental agencies, departments, and with private vendors; a thorough knowledge of computer hardware and software; a thorough knowledge of computer systems networking; and related capacities and abilities.

**EDUCATION AND EXPERIENCE:**

Education: Such as may have been gained through: Possession of a Master's Degree from a college of recognized standing with specialization in Accounting, Business Administration, Public Administration, or Certification as a Certified Public Accountant; and Experience: Such as may have been gained through: considerable employment in a highly responsible administrative position involving significant responsibility for governmental financial management. Or, any combination of education and experience that shall be substantially equivalent to the above education and experience.







# NOTICE OF PUBLIC MEETING

The Northern Middlesex Metropolitan Planning Organization (NMMPO) will meet at 2:30 P.M.on June 28, 2017 at the Northern Middlesex Council of Governments office, 40 Church Street, Suite 200, Lowell, MA. The NMMPO willtake action on several amendments to the FFY 2017-2021 Transportation Improvement Program (TIP).The full agenda can be found at www.nmcog.org. Please note that the TIP contains the program of projects for the Lowell Regional Transit Authority (LRTA). The MPO's public participation process satisfies the LRTA's public participation requirements for the program of projects.

Notice: This location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance, free of charge, upon request (including, but not limited to, interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org . Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

# សេចក្តីជូនដំណឹងស្តីពីការរៀបចំកិច្ចប្រជុំជាសាធារណៈ

អង្គភាពរៀបចំក្រុង ន័សធន មីុដូលសិច (Northern Middlesex Metropolitan Planning Organization) ហៅកាត់ NMMPO នឹងធ្វើការរៀបចំកិច្ចប្រជុំជាសាធារណៈមួយនៅម៉ោង២:៣០នាទីរសៀល ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៧ នៅការិយាល័យក្រុមប្រឹក្សាភិបាល ន័សធន មីុដូលសិច ( Northern Middlesex Council of Governments) ដែលមានទីតាំងស្ថិតនៅផ្លូវ៤០ Church Street, Suite 200, Lowell, MA ។ អង្គភាពរៀបចំក្រុង ន័សធន មីុដូលសិច នឹងធ្វើការអនុវត្តន៍លើវិសោធនកម្មមួយចំនួនចំពោះគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ ២០១៧-២០២១ ។ លោកអ្នកអាចទទួលបានព័ត៌មានពីរបៀបវិរៈនៃកិច្ចប្រជុំនេះទាំងស្រុងដោយគ្រាន់តែចូលទៅកាន់វេបសាយ www.nmcog.org ។ សូមបញ្ជាក់ថា ក្នុងគម្រោង TIP នេះ មានរួមបញ្ចូលទាំងកម្មវិធីនៃគម្រោងជាច្រើន សម្រាប់អាជ្ញាធរដឹកជញ្ជូនថ្នាក់តំបន់ឡូវែល (LRTA) ។ ដំណើរការរៀបចំចូលរួមជាសាធាណៈរបស់អង្គភាពរៀបចំក្រុងនេះ គឺវាស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរឡទ្រៅចំពោះកម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន ។

**កំណត់ចំណាំ:** ទីតាំងនៃការរៀបចំកិច្ចប្រជុំនេះ ងាយស្រួលសម្រាប់ឱ្យជនពិការចេញចូល និងនៅជិតនិងចំណតឡានក្រុង ។ អង្គភាព NMMPO មានទីតាំងសុវត្ថភាពសម្រាប់ចំណតកង់ដែលស្ថិតនៅជាន់ទី២ ។ សម្រាប់ជំនួបនេះ NMMPO ក៏ផ្តល់ផងដែរនូវការស្នាក់នៅដ៏សមរម្យ និង,រឺជំនួយផ្នែកភាសាដោយមិនគិតថ្លៃ ប្រសិនបើមានការស្នើរសុំ( មានដូចជាអ្នកបកប្រែជាភាសាអង់គ្លេស និងភាសាផ្សេងទៀត, បកប្រែភាសាដោយមើល រឺស្តាប់តាមរយៈវីដេអូសម្រាប់អ្នកពិការភ្នែក និងថ្លង់, ឧបករណ៍បកប្រែជាសម្លេងសម្រាប់អ្នកគរថ្លង់ និងជនពិការភ្នែក ព្រមទាំងការចែកជូនឯកសារផ្សេងទៀតបតាមដែលមាន ។

សម្រាប់ការចូលរួមរបស់លោកអ្នក និងជំនួយបន្ថែម សូមទំនាក់ទំនងលោក Justin Howard តាមរយៈលេខទូរស័ព្ទ (978) 454-8021, ext 121 រឺអ៊ីមែលទៅកាន់ jhoward@nmcog.org ។ រាល់ការស្នើរសុំជំនួយនានា ដូចជាភាសាកាយវិកា, ការបកប្រែផ្ទាល់ៗ រឺការបកប្រែភាសា សូមទំនាក់ទំនងមកយើងខ្ញុំឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីងាយស្រួលក្នុងការរៀបចំ ។

KhmerPost USA

Cambodian American Biweekly Newspaper

# ផ្សព្វផ្សាយទៅដល់អ្នកអានក្នុងសហគមន៍ខ្មែរច្រើនជាងគេបង្អស់នៅសហរដ្ឋអាមេរិក

កាសែតខ្មែរផុស ស.រ.អា គឺជាកាសែតភាសារខ្មែរ- អង់គ្លេសពណ៌ធម្មជាតិ មានចំនួន៣២ទំព័រដែលបោះពុម្ពផ្សាយជារៀងរាល់ពីរសប្តាហ៍ម្តងចំនួន៥,០០០ច្បាប់ និងធ្វើការបែងចែកដោយមិនគិតថ្លៃទៅកាន់៦០កន្លែងក្នុងតំបន់ឡូវែល។ រៀបចំពេលវេលាផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ឆ្នាំ២០១៧ របស់លោកអ្នកជាមួយយើងខ្ញុំថ្ងៃនេះ!

Connecting 50,000 Khmer-speaking readers per month.
Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

<u>កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ :</u>

- ថ្ងៃទី ១២ និង ២៦ ខែមិថុនា
- ថ្ងៃទី ១០ និង ២៤ ខែកក្កដា
- ថ្ងៃទី ០៧ និង ២១ ខែសីហា
- ថ្ងៃទី ១១ និង ២៥ ខែតុលា
- ថ្ងៃទី ០៩ និង ២៣ ខែកញ្ញា
- ថ្ងៃទី ០៦ និង ២០ ខែវិច្ឆិកា
- ថ្ងៃទី ០៤ និង ១៨ ខែធ្នូ

**<u>2017 Print Dates</u>**

- June 12, 26
- July 10, 24
- August 07, 21
- September 11, 25
- October 09, 23
- November 06, 20
- December 04, 18



**Soben Pin, Co-founder/Managing Partner;
Sochet Chhen, Office Coordinator**

* រាល់ព័ត៌មាននៃការផ្សព្វផ្សាយទាំងអស់ ត្រូវផ្ញើមកកាន់យើងខ្ញុំឲ្យបាន ៣ ថ្ងៃមុនការបោះផ្សាយ។

**ទំនាក់ទំនងមក ពិន សុបិន សម្រាប់ឱកាសនៃការផ្សព្វផ្សាយពាណិជ្ជកម្មរបស់លោកអ្នក**

**Contact Soben Pin For Advertising Opportunities**
**Email: sobenpin@khmerpost.us**
**978-677-7163**

ម៉ោងបំរើការងារ: ថ្ងៃច័ន្ទ - សុក្រ ចាប់ពី 9:00 ព្រឹក ដល់ម៉ោង ៤:00 ល្ងាច
អសយដ្ឋានការិយាល័យ**កាសែតខ្មែរផុសស.រ.អា**

**Office: KhmerPost USA, LLC. 45 Merrimack St. Suite 218A. Lowell, MA 01852**
**Hours: Monday – Friday. 9AM – 4PM**
**VISIT KHMERPOST.US**



សុខភាពទាំងមូលរបស់មនុស្សចាស់

ផែនការមួយ
សម្រាប់មនុស្សចាស់អាយុ
65 ឆ្នាំឬចាស់ជាងនេះជាមួយទាំង
Medicare និង
MassHealth។

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

យើងអាចជួយបាន

1-888-566-3526 (ទូរស័ព្ទឥតគិតថ្លៃ) ▪ TTY/TDD: 711 ▪ www.seniorwholehealth.com



សហគមន៍ធនាគារដែលជួយអ្នក
សម្រាប់កសាងអនាគត

- គណនេយ្យមានសែក
- គណនេយ្យសន្សំប្រាក់
- ខ្ចីប្រាក់

យើងមានផ្តល់ជូនច្រើនទៀត
យើងមានបុគ្គលិកដែលនិយាយភាសាខ្មែរ

Washington
SAVINGS BANK
We give you more

រី ខង
(978) 569-1623
NLMS# 764613

washingtonsavings.com
Member FDIC/ Member DIF

*For your special day...*
សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

UMASS LOWELL
Inn & Conference Center

សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ
ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ
លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។
គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**